Free
សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

7 Video
ផ្ញើឥវ៉ាន់ទៅវិញទៅមកពីអាមេរិកនិងកម្ពុជា តាមយន្តហោះ២ថ្ងៃដល់
ផ្ញើ១ផោន តម្លៃ១០ដុល្លារ ធានាមិនបាត់ -ជើងធ្វើដំណើរមានរាល់សប្តាហ៍
**ទទួលឥវ៉ាន:** ថ្នាំពេទ្យ -ខោអាវ-ស្បែកជើង-ទូរស័ព្ទ-គ្រឿងបន្លាស់-គ្រឿងអលង្ការ
សូមទូរស័ព្ទមកលោក យុទ្ធ 978-876-1985 ដើម្បីឱ្យដឹងថ្ងៃផ្ញើ
660 Middlesex St. Lowell, MA 01851
978-710-6356

## MINISTRY, CAMBODIAN JOURNALISTS STRENGTHEN LINKS TO CHINA



**by AunPheap | April 11, 2017**

Information Ministry officials and state-affiliated Cambodian journalists will receive training from and pay visits to their Chinese counterparts under a new agreement signed by the two countries on Monday.

**Continued to Page 13**

# មហាសង្ក្រាន្តឆ្នាំថ្មី: ឆ្នាំរកា នព្វស័ក ទេវតាឆ្នាំថ្មី ព្រះនាម

## ឝុិកិមិរាទេវី ចុះនៅម៉ោង៣:១២នាទីទៀបភ្លឺ ឈានចូលថ្ងៃសុក្រ ទី១៤ ខែមេសា?!



អបអរពិធីលើកទង់ជាតិខ្មែរនៅទីក្រុងឡូវែល នាឱកាសចូលឆ្នាំខ្មែរ

**ភ្នំពេញ:** មហាសង្ក្រាន្តឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ២៥៦១ គ្រឹស្តសករាជ ២០១៧ មហាសករាជ ១៩៣៩ ចុល្លសករាជ **តទៅទំព័រទី ០៩**

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ


978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៏
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

ការិយាល័យច្បាប់
រ៉ូសា និង តាំង

Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា

Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង
Law Office of
Rosa & Taing
ATTORNEY AT LAW
SERVICES
• Auto Accidents/ Personal Injury
• Bankruptcy
• Immigration
• Consumer Protection
• Real Estate Closings/Disputes
• Divorces Child Custody
តំណាងក្តីដូចខាងក្រោម
• គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
• ក្ស័យធន
• អន្តោប្រវេសន៍
• ការពារអតិថិជន
• ទំនាស់ផ្នែកអចលនវត្ថុ
• លែងលះ និងអាណាព្យាបាលកិច្ច
1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com

# បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីរពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្របទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

## អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

## បុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ !

# តើបុណ្យនេះមានប្រវត្តិបែបណា ?

**ភ្នំពេញៈ** បុណ្យចូលឆ្នាំថ្មី គឺជាបុណ្យប្រពៃណីជាតិដ៏ធំរបស់ប្រជាជនខ្មែរ។ ឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ២៥៦១ គ្រឹស្តសករាជ២០១៧នេះ ត្រូវចូលមកដល់នៅថ្ងៃសុក្រ ៣រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស.២០១៧ វេលាម៉ោង ០៣ៈ១២នាទីទៀបភ្លឺ។

ទេវតាឆ្នាំថ្មីនេះ ព្រះនាម "កិមិរាទេវី" ជាបុត្រីទី៦ នៃកបិលមហាព្រហ្មទ្រង់គង់នៅចាតុម្មហោរាជិការទ្រង់អម្ពរពណ៌ សេត លម្អនៅ ព្រះកាណ៌ ដោយបុប្ផ ចង្កុរណី អភរណៈ កែវបុស្សរាគ័ម ភក្សាហារទញ្ញរង់ ចេកណាំវ៉ា ព្រះហស្តស្តាំទ្រង់ ព្រះខ័ន្ធ ព្រហស្តឆ្វេងទ្រង់ពិណ ទ្រង់គង់ផ្ទំបិទព្រះនេត្រ លើខ្នង មហឹង្សា (ក្របី) ជាពាហនៈ។

ដើម្បីចូលរួមអបអរដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ យើងខ្ញុំសូមលើកយកនូវប្រវត្តិបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាខ្មែរជូនប្រិយមិត្តអ្នកអានស្វែងយល់ដូចខាងក្រោមៈ

*** ប្រវត្តិបុណ្យចូលឆ្នាំថ្មីៈ**

តំណាលថា កាលដើមនៃភទ្ទកប្ប មានសេដ្ឋីនាយម្នាក់មានបុត្រម្នាក់ឈ្មោះ ធម្មបាលកុមារ ជាអ្នកមានចំណេះវិជ្ជាដ៏វិសេសវិសាលរៀនចេះចប់គម្ពីរត្រៃវេទ តាំងពីអាយុ៧ឆ្នាំមកម្ល៉េះ។ សេដ្ឋីនាយជាបិតាបានសាងប្រាសាទមួយឱ្យនៅ





ទៀបដើមជ្រៃមួយដ៏ធំក្បែរឆ្នេរទន្លេដែលជាទីនៅនៃបក្សីទាំងឡាយ។ ធម្មបាលកុមារនោះ បានចេះទាំងភាសាបក្សីទាំងពួងផង ហើយក្លាយជាអាចារ្យសម្តែងមង្គលផ្សេងៗដល់មនុស្សទាំងពួងផងដែរ។

គ្រានោះមនុស្សលោករមែងរាប់អានព្រះ-មហាព្រហ្ម និងកបិលមហាព្រហ្មមួយអង្គទៀត ដែលជាអ្នកសម្តែងមង្គលដល់មនុស្សទាំងពួង ដូចគ្នាដែរ។ ពេលនោះ កបិលមហាព្រហ្មបាន ជ្រាបព័ត៌មានរឿងធម្មបាលកុមារ ក៏ចុះមកសួរបញ្ហាជាមួយចៅធម្មបាលកុមារនូវប្រស្នាចំនួន ៣ខ ដោយទ្រង់ដាក់លក្ខខណ្ឌថា "បើចៅដោះប្រស្នារបស់យើងបានយើងនឹងកាត់ព្រះសិរសាបូជាជូនចៅឯង តែបើចៅឯងដោះប្រស្នាយើងមិនរួចទេ ចៅឯងត្រូវកាត់ក្បាលថ្វាយដល់យើងវិញ"។ ធម្មបាលកុមារក៏សុំឱ្យពន្យារពេលចំនួន៧ថ្ងៃសិន ដើម្បីគិតដោះប្រស្នា។

លុះកន្លងទៅ៦ថ្ងៃហើយ ក៏នៅតែគិតមិនឃើញ ចៅធម្មបាលកុមារដឹងខ្លួនថា ព្រឹកស្អែកនឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្មជាប្រាកដហើយ។ ដូច្នេះគួរតែរត់ទៅលាក់ខ្លួនពួនអាត្មាសិនប្រសើរជាង។ គិតហើយធម្មបាលកុមារបានចុះពីប្រាសាទទៅដេកពួននៅក្រោមដើមត្នោតមួយដើម។ ដើមត្នោតនោះ មានសត្វឥន្ទ្រីញី-ឈ្មោល ធ្វើសំបុកអាស្រ័យនៅ។

វេលាយប់ឥន្ទ្រីញីសួរទៅឥន្ទ្រីឈ្មោលថា "ព្រឹកនេះយើងបានអាហារពីណាស៊ី?", ឥន្ទ្រីឈ្មោលឆ្លើយថា "យើងនឹងស៊ីសាច់ធម្មបាលកុមារដែល

**តទៅទំព័រទី ១៧**


*For your special day...*

*សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក*



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL
Inn & Conference Center

សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ
ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ
លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្ករកូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន។

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# Trinity EMS ជាក្រុមហ៊ុនផ្លូវការតែមួយគត់ សម្រាប់សេវារថយន្តសង្គ្រោះបន្ទាន់ក្នុងរដ្ឋម៉ាសាជូសេត

ក្រុមហ៊ុន Trinity EMS ដែលបានបង្កើត ឡើងក្នុងឆ្នាំ១៩៩១ ដោយលោក John Chemaly និង លោក Gary Sepekal ថ្ងៃទី១៦ ខែមិនា ឆ្នាំ ២០១៧ ត្រូវបានទទួលស្គាល់ជាក្រុមហ៊ុនដែលបំរើសេវាសង្គ្រោះបន្ទាន់ល្អបំផុត បន្ទាប់ពីមានការវាយតំលៃរបស់គណៈកម្មការ Accreditation of the International Academies of Emergency


រូបពីឆ្វេងមកស្តាំ: លោក Gary Sepe អគ្គនាយករង, លោក Jon Kelly នាយកផ្នែកទូរគមនាគមន៍ និងព័ត៌មានវិទ្យា, លោក Chris Archambault ជំនួយការផ្នែកទូរគមនាគមន៍ និងលោក John Chemaly អគ្គនាយក



Dispatch (IAED) ។

ការទទួលស្គាល់នេះ គឺមានន័យថា ក្រុមហ៊ុន Trinity EMS បានក្លាយជាក្រុមហ៊ុនផ្លូវការតែមួយគត់ក្នុងការផ្តល់សេវារថយន្តសង្គ្រោះបន្ទាន់នៅក្នុងរដ្ឋម៉ាសាជូសេត។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏ទទួលបានលំដាប់លេខរៀងទី២៣១ក្នុងចំណោមក្រុមហ៊ុនចំនួនប្រហែល៣,២០០ ដែលបច្ចុប្បន្នកំពុងបំរើសេវាសង្គ្រោះបថមទូទាំងពិភពលោក ។

បន្ទាប់ពីការទទួលស្គាល់ជាផ្លូវការនេះ លោក JonhChemaly អគ្គនាយកក្រុមហ៊ុន Trinity EMS បានមានសាសន៏ថា "យើងពិតជារំភើបដែលទទួលបានការទទួលស្គាល់ជាផ្លូវការដ៏មានសារៈសំខាន់បែបនេះ ហើយប្រការនេះមិនត្រឹមតែធ្វើក្រុមហ៊ុនរបស់យើងកាន់តែប្រសើរនោះទេ វាថែមទាំងពង្រឹងគោលបំណងរួមរបស់យើងជាមួយនឹង IAED ក្នុងការធ្វើឱ្យប្រសើរឡើង សុវត្ថិភាពសាធារណៈ និងបង្កើនប្រសិទ្ធិភាពប្រព័ន្ធ៩១១ឱ្យដល់កម្រិតអតិបរមាថែមទៀតផងដែរ..។ ដោយឡែកលោក Chris Archam bault ដែលជាជំនួយនាយកផ្នែកទូរគមនាគមន៏របស់ Trinity បានលើកឡើងថា ហេតុផលចំបងបំផុតនៃជោគជ័យក្នុងការទទួលស្គាល់ជាផ្លូវការនេះ គឺដោយសារការលះបងរបស់ក្រុមការងារទាំងមូល និងទំនុកចិត្តលើការគ្រប់គ្រង។

ក្នុងសហរដ្ឋអាមេរិកវិញមានក្រុមហ៊ុនសរុបចំនួន១៨៤ដែលត្រូវបានទទួលស្គាល់ផ្លូវការសម្រាប់បំរើសេវារថយន្តសង្គ្រោះបន្ទាន់ក្នុងរដ្ឋទាំង៥០។ ក្នុងនោះក្រុមហ៊ុន Trinity EMS មានប្រតិបត្តិការណ៏គ្រប់ដណ្តប់ក្រុងចំនួន១៣តាមរយៈកិច្ចសន្យាប្រព័ន្ធ៩១១ដោយមានបុគ្គលិកចំនួន២៧០នាក់និងរថយន្តសង្គ្រោះចំនួន៧៥ដែលមានគោលដៅរងចាំបំរើសេវាចំនួន៨ កន្លែងទូទាំងរដ្ឋមេរី ម៉ាកវាលី និងញូហ៊ាមស័រភាគខាងត្បូង៕

**ប្រែសម្រួលដោយ សុខារ័ត្ន កួយ**



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare Home Care Agency

Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# កម្មវិធីក្រោយម៉ោងសិក្សានៅសមាគមខ្មែរទទួលបានលទ្ធផលប្រសើរ

**ខ្មែរផុសស.រ.អា.**

**ឡូវែល:** សិស្សក្មេងៗបានមកចូលរួមក្នុងកម្មវិធីថ្មី"ក្រោយម៉ោងសិក្សា"នៅសមាគមខ្មែរដូចធម្មតា, កាលពីរសៀលម្សិលមិញ លោកគ្រូសុវណ្ណ ឃន បានមកបង្ហាត់សិស្សពីគ្រឿងភ្លេងខ្មែរ, រីឯថ្ងៃសុក្រទី៧មេសានេះសិស្សរំលឹកឡើងវិញនូវមេរៀនដែលបានសិក្សាពីមុនៗមក, តែអ្វីដែលយើងចង់ដឹងនោះថា "តើក្មេងៗទទួលបាននូវលទ្ធផលដូចដែលអ្នកគ្រូស្រីពៅរង់ចាំដែរឬទេ?" យើងបានសុំឱ្យអ្នកគ្រូនាំក្មេងៗឱ្យអង្គុយដឹកង់ហើយនិយាយពីអារម្មណ៍របស់ពួកគេ។ គួរឱ្យភ្ញាក់ផ្អើលណាស់ នៅពេលឃើញសិស្សប៉ុណ្ណារូចង់មកមកធ្វើកិច្ចការដែលគ្រូបានដាក់ឱ្យធ្វើពីសាលាមកយកមកធ្វើនៅឯសមាគមខ្មែរ ហើយនៅ២សប្តាហ៍ចុងក្រោយនេះ កិច្ចការធ្វើបានចប់សព្វគ្រប់ ហើយនៅមានពេលសម្រាប់លេងជាមួយមិត្តភក្ត្រជាកូនខ្មែរដូចគ្នា មានពេលរៀនពីវប្បធម៌របស់ឪពុកម្តាយខ្លួន ហើយជាពិសេសចេះសំពះលាអ្នកគ្រូជាមួយនឹងពាក្យថា"ជំរាបលាអ្នកគ្រូ" ទៀតផង។ ប៉ុណ្ណារ៉ូនិយាយថា "ពិន្ទុនៅសាលារបស់ខ្លួនបានឡើងប្រសើរវិញហើយ បន្ទាប់ពីធ្វើកិច្ចការដែលដាក់ឱ្យពីសាលាមកធ្វើបានគ្រប់គ្រាន់។ កុមារីម្នាក់និយាយថា "ខ្លួនបានរៀនរាប់អក្សរខ្មែរថ្ងៃខ្មែរ



នឹងខែខ្មែរ បានយ៉ាងចាំមាត់ ទៅហើយ" រីឯកុមារាម្នាក់ទៀត មិនមែនជាសិស្ស "ក្រោយម៉ោងសិក្សា" របស់សមាគមខ្មែរទេ ជាសិស្សមានអាយុ១១ឆ្នាំរៀននៅថ្នាក់ទី៩ គេមកសមាគមដោយសារ "ស្ម័គ្រចិត្តមកជួយកិច្ចការរបស់សិស្ស"ណាចង់ឱ្យគេបានជួយកិច្ចការរបស់គេផ្ទាល់បានធ្វើរួចរាល់អស់ហើយ។

សក្ខីកម្មរបៀបនេះ គឺជាពិន្ទុប្រសើរបំផុតសម្រាប់សមាគមខ្មែរ គួររៀបជាគម្រោងធំមួយសម្រាប់រៀបអនាគតសហគមន៍ខ្មែរឱ្យអាចសម្បូរគ្រួសារដែលមានកូនចៅជោគជ័យក្នុងការសិក្សាឱ្យបានច្រើនជាអតិបរិមាបាន ពីព្រោះ "កម្មវិធីក្រោយម៉ោងសិក្សា"នេះជាកាំច្រវ៉ាក់ដែលខ្វះក្នុងសហគមន៍ ។ កន្លែងជាច្រើនដែលសមាគមខ្មែរគួរតែសម្លឹងដាក់ភ្នាក់ងាររបស់ខ្លួនឱ្យទៅជួយកូនខ្មែរបន្ថែម ដូចជានៅវត្តអារាមក្នុងក្រុងជាដើម មានវត្តជាច្រើនដែលយាយតាតែងនាំចៅទៅលេងមកទល់ពេលនេះវត្តទាំងនោះគ្មានកម្មវិធីរបៀបនេះទេ នឹកទៅជំនាន់ដើមវត្តអារាមមានតួនាទីរំដោះជាតិដោយការសិក្សានៅគ្រប់ជំនាន់ដែរ ។



អ្នកគ្រូស្រី ពៅ

សិស្សនឹងគ្រូទាំងអស់ដែលបានជួបពិភក្សាជាមួយយើងនៅសមាគមខ្មែរ បានសម្តែងការរីករាយពេញចិត្តនឹងកម្មវិធីដឹកនាំដោយក្រុមអ្នកគ្រូស្រីពៅ ដែលបានបំពេញការខ្វះខាតក្នុងការអប់រំរបស់គ្រួសារខ្មែរមួយចំនួន គឺជាហេតុធ្វើឱ្យឪពុកម្តាយកុមារាកុមារីត្រេកអរដោយបានជួបកម្មវិធីសម្រាប់ខ្លួនរបៀបនេះ ។ លទ្ធផលប្រសើរនៅពេលសង្កេតឃើញថា "ក្មេងៗចេះនឹកចង់ទៅ CMAA, ពេលដល់ម៉ោងចេញមិនចង់មកផ្ទះវិញ, ក្មេងចេះមានទម្លាប់គួរសមប្រសើរជាងមុន, កិច្ចការសាលាធ្វើបានចប់គ្រប់គ្រាន់" គឺប្រាកដជាជំនួយប្រកែកមិនបានដល់គ្រួសារខ្មែរ កាត់ថ្លៃក៏មិនបានដែលសមាគមខ្មែរបំរើសហគមន៍ទាំងអស់ដោយមិនមានយកកំរៃ ៕






# អនាគតសិស្សវិទ្យាល័យឡូវែលនៅក្នុងកណ្តាប់ដៃសាលាក្រុង

## “The future of Lowell H.S. is in hand of City Councilors”

**ដោយ សុបិន ពិន**

ថ្វីត្បិតតែមានការសួរយោបល់ប្រជាពលរដ្ឋជាឪពុកម្តាយនឹងជាម្ចាស់ឆ្នោតដោយសាលាក្រុងឡូវែលក៏ដោយ, លោក វ៉ាស្នា នួន អតីតសមាជិកក្រុមប្រឹក្សាក្រុងឡូវែលបានឧទ្ទានថា ″ការសួរយោបល់នេះ គ្រាន់តែជាឆាកល្ខោនធ្វើឱ្យល្អមើលតែប៉ុណ្ណោះ ពីព្រោះគេបានដឹងលទ្ធផលរួចជាស្រេចទៅហើយ!″ បើជាយ៉ាងដូច្នោះមែន គឺពិតជាចំអកឱ្យសហគមន៍ខ្មែរនឹងស្បានីសខ្លាំងពេកហើយ។ ថ្មីៗនេះ ខ្មែរផុសស.រ.អា.បានលើកបទវិភាគជាច្រើនសម្រាប់ជាវិភាគទានជូនលោកអ្នកអានឱ្យអាចធ្វើសេចក្តីសម្រេចចិត្តជ្រើសយកកន្លែងណាមួយសម្រាប់សង់វិទ្យាល័យដែលអាចជួយដល់ការសិក្សាដល់កូនចៅសង្គមខ្លួនឯងជាជនជាតិភាគតិចឱ្យអាចបញ្ចប់មធ្យមសិក្សារបស់ខ្លួនប្រកបដោយជោគជ័យបានកន្លងមកលទ្ធផលនៃការសិក្សានៅទាបណាស់ឆ្ងាយពីសេចក្តីប្រាថ្នារបស់ម្តាយឪពុក។

ខ្មែរផុសបានផ្តល់ការវិភាគជាបន្តបន្ទាប់ថាមានកត្តាជាច្រើនដែលបង្ហាញថា″វិទ្យាល័យឡូវែលគួរតែមានទីតាំងនៅក្រៅទីក្រុង″ទើបសិស្សានុសិស្សអាចរៀនសូត្រក្នុងបរិយាកាសស្ងប់ស្ងៀមបានពីព្រោះ

**កត្តា១**-សាលាត្រូវការភាពស្ងប់ស្ងៀមដែលនៅក្នុងក្រុងសម្លេងចរាចរនៃរថយន្តធំតូចសម្លេងឡានទឹក ឡានពេទ្យ សម្លេងអ៊ូអរ ព្រឹត្តិការណ៍នៃទីក្រុងសុទ្ធតែរំខានភាពស្ងប់ស្ងាត់នៃសាលារៀនជាប្រចាំថ្ងៃ -

**កត្តា២** -កូនសិស្សដើរកាត់ទីក្រុងតែងប្រទះហាងលក់ដូរដែលទាក់អារម្មណ៍របស់ពួកគេមានផ្ទះលក់កាហ្វេមានទៀមលក់សុរា ឬគ្រឿងស្រវឹងផ្សេងៗពេលខ្លះទំនិញមួយចំនួន គឺជាទំនិញដ៏សែនគ្រោះថ្នាក់ ដូចជាកញ្ឆា-អាភៀនជាដើម ដែលជនអនាថានៅចែកចាយក្រោមច្រមុះប៉ូលិសនៅឡើយ...កូនខ្មែរជាច្រើនហើយធ្លាប់បានឆ្លងព្រឹត្តិការណ៍ដ៏គួរឱ្យរន្ធត់នោះ ខ្លះក៏មានទោសត្រូវគេចាប់និរទេសទៅស្រុកខ្មែរមិនទាន់ចប់នៅឡើយ...

**កត្តា៣**- មានមនុស្សមិនគប្បីជាច្រើន ដែលរំខានដល់សន្តិសុខរបស់សិស្សថ្មើរជើងទៅកាន់វិទ្យាល័យរបស់ខ្លួន ជនទាំងនោះមានជនគ្មានទីលំនៅប្រាកដជនក្រីក្រកឹកស្រវឹងខ្ជបឈររេរាតាមដងវិថី ឬអង្គុយរំខានជណ្តើរការិយាល័យនានា... អ្នកទាំងនោះមិនគ្រាន់តែសុំទាន ឬសុំបារីមួយដើម ឬក៏សុំភ្លើងអុចបារីតែប៉ុណ្ណោះទេ គេដោះដូរទំនិញគ្រឿងញៀនយ៉ាងចំណានទៀតផង...ឪពុកម្តាយខ្លះភ្ញាក់ស្មៀតមានវិប្បដិសារីដោយបានបណ្តោយឱ្យកូនដើរទៅរៀនតាមដងផ្លូវនៃទីក្រុង




ឡូវែលតែម្តង២ដងសោះ ក៏ហួសពេលខូចកូនកែលែងបាន។

កត្តាទាំង៣នោះ ជាគុណវិបត្តិរបស់ ″ក្រុងឡូវែល″មកលើផ្នែកមួយក្នុងវិស័យអប់រំរបស់បណ្តាកូនសិស្សជាជនជាតិភាគតិច។ គួរចងចាំថាយុវជនជាសិស្សវិទ្យាល័យនៅផុយស្រួយជាទីបំផុតប្រឈមនឹងគ្រោះថ្នាក់នៅតាមផ្លូវ ហើយបំផ្លាញការសិក្សានឹងអប់រំបានយ៉ាងងាយស្រួលតែមួយប៉ប្រិចភ្នែកតែប៉ុណ្ណោះ ។ បន្ថែមពីលើគ្រោះថ្នាក់នៅ″តាមដងផ្លូវ″ទាំងនោះជនជាតិភាគតិចខ្មែរយើង ក៏មានប្រឈមនឹងគ្រោះថ្នាក់មួយទៀតដែលរំខានការសិក្សារបស់កូនចៅ គឺ ″គ្រោះថ្នាក់នៅផ្ទះ″និមួយៗ,ឪពុកម្តាយចេញទៅប្រកបរបរចិញ្ចឹមជីវិត តាំងពីព្រលឹមទៅដល់យប់ព្រលប់មិនបានជួបមុខកូនទេ ម្ល៉ោះហើយកិច្ចការសាលារៀនដែលប្រគល់មកឱ្យឪពុកម្តាយជួយដល់កូនខ្លួនក៏ខ្វះខាត។ ដូច្នេះសម្រាប់កូនខ្មែរយើងដែលជាជនជាតិភាគតិចនាំគ្នាមានសង្ឃឹមតែទៅលើផ្នែកកម្មវិធី″ក្នុងសាលារៀន″តែប៉ុណ្ណោះ ដែលមានសន្តិសុខគ្រាន់បើ ចំណែកនៅក្រៅសាលានឹងនៅផ្ទះកូនចៅសហគមន៍យើងធ្លាប់មានការខូចខាតខាងមធ្យមសិក្សាជាដំណំរួចទៅហើយ...សង្ឃឹមថាមាតាបីតាជំនាន់ទី៣-ទី៤ក្រោយៗមកមានការយល់ដឹងពីវប្បធម៌អប់រំកូនចៅតាមច្បាប់នៃសហរដ្ឋអាមេរិក ទើបការពារកូនចៅឱ្យទទួលការអប់រំប្រសើរបាន។ ដូច្នេះដំណោះស្រាយគឺ ″យកសាលាមធ្យមសិក្សាចេញពីកណ្តាលក្រុង -ដឹកសិស្សានុសិស្សដោយរថយន្តលឿងទៅមកពីផ្ទះទៅសាលារៀន -នឹងប្រើកម្មវិធីធ្វើកិច្ចការសាលាក្រោយម៉ោងរៀនឱ្យហើយមុននឹងមកផ្ទះវិញ″ ការជ្រើសយកកន្លែងសង់សាលាថ្មីនៅ″កីឡាដ្ឋានខលី-បែលវីឌា″គឺប្រសើរណាស់។

បុព្វហេតុចម្បងមួយទៀត ដែលគួរតែសម្រេចប្តូរទីតាំង″វិទ្យាល័យឡូវែលចេញទៅក្រៅប្រជុំជន″ ពីព្រោះវានឹងក្លាយជាព្រឹត្តិការប្រវត្តិសាស្ត្រដែលអាចប្តូរមុខមាត់ឡូវែលសម្រាប់១០០ឆ្នាំទៅមុខទៀត ហេតុអ្វី?

**១-**បើសាលាមិនប្តូរទីកន្លែងទេ នៅ៥ឆ្នាំទៅមុខតំបន់កណ្តាលក្រុងនឹងក្លាយជា ″ក្រុងស្ទះចរាចរ″ដោយអាគារក្រសួងយុត្តិធម៌ថ្មី នាំបុគ្គលិក៨០០នាក់ថ្មីមកកណ្តាលក្រុង, ជាមួយនឹងវិទ្យាល័យឡូវែលថ្មីក៏នាំសិស្សានុសិស្ស៤០០០នាក់ចេញចូលរាល់ព្រឹកនឹងល្ងាច។ ភូមិដ្ឋាននៃតំបន់កណ្តាលក្រុងនៅតែជាទីកន្លែងដែលពាណិជ្ជកររកស៊ី″មិនកាក់កប″ហើយបិទហាងជាបន្តបន្ទាប់ដដែល ពីព្រោះជាទីក្រុងចង្អៀត ហើយគ្មានអ្នកជិតខាងនឹងអ្នកដំណើរដែលសម្បូរលុយ។

**២-**តែបើវិទ្យាល័យប្តូរទីតាំងទៅវិញ ទីក្រុងក៏បានបន្ធូរចរាចរមនុស្សបាន៤០០០នាក់ ដែលចេញទៅមិនឆ្ងាយ ហើយនៅទីនោះសាលារៀនថ្មីទំនើបនៅជាប់នឹងកីឡាដ្ឋានជាទីតាំងមានន័យនឹងគោលដៅវប្បកម្មដូចគ្នាជំរះគុណវិបត្តិច្រើនយ៉ាង។ រីឯនៅកណ្តាលក្រុងឡូវែលវិញ ទីក្រុងសេដ្ឋកិច្ចនឹងចូលមកជំនួសក្រុងឡូវែលចាស់ធ្វើឱ្យក្រុងវប្បធម៌ចំណាស់រស់ឡើងវិញ ជាក្រុងទំនើបនាំទេសចរនឹងប្រាក់ចំណូលសម្រាប់ឧបត្ថម្ភក្រុងនឹងគុណភាពកម្មវិធីសិក្សាបានថែមទៀត។

**៣-**នៅពេលដែលតំបន់កណ្តាលក្រុងឡូវែលក្លាយជាតំបន់សេដ្ឋកិច្ចចំណូលពន្ធដារនឹងកើនចំនួនការប្រយុទ្ធនឹងភាពអនាថា នឹងកែរលំអរបាន, តំបន់ក្រីក្រក៏ក្លាយទៅជាកន្លែងរកស៊ីបានរួមទាំង″ក្រុងខ្មែរ″ឬ″ក្រុងស្បានីស″ដែលនៅក្បែរគ្នានោះ, ដូច្នេះនៅ១០ឆ្នាំខាងមុខគេអាចនិយាយពីឡូវែលថា ″ជាក្រុងដែលងាយស្រួលរស់ប្រសើរបាន″

ក៏ប៉ុន្តែនៅពេលដែលលោក វ៉ាស្នា នួន និយាយថា អ្វីៗបានសម្រេចរួចជាស្រេចហើយនោះ គេអាចនឹកភ្លាមទៅដល់គំនិតថា″នៅក្នុងគណក្រុមប្រឹក្សាក្រុងឡូវែលមានសមាជិកមកពីតំបន់បែលវីឌា៦រូបទៅហើយក្នុងចំណោម៩រូប ដែលមិនចង់ឃើញតំបន់របស់ខ្លួនសម្បូរដោយជនជាតិភាគតិចឆ្លងកាត់ច្រើននៅទីនោះទេ!″ គេក៏អាចនឹកទៀតថាថ្វីត្បិតតែបែលវីឌាជាតំបន់ស្រស់ស្អាតស្ងប់ស្ងាត់ក៏មានមនុស្សដែលមានចិត្តទូលំទូលាយចង់រួមរស់ជាមួយក្រុមមនុស្សផ្សេង ដែលមានធ្លាប់វប្បធម៌អរិយធម៌ខ្ពង់ខ្ពស់ច្រើនពាន់ឆ្នាំមកហើយនឹងចង់ឃើញអ្នកទាំងនោះមានសន្តិសុខនឹងសុភមង្គលនៅក្នុងក្រុងឡូវែលតែមួយជាមួយគ្នា ដូចខ្លួនជាមហាគ្រួសារតែមួយដែរ៕





Do you want Lowell High School to be:
- 100% new & modern high school?
- Most efficient and effective for best learning?
- Safe and without disruption to learning?
- A more collaborative, campus setting?

**Say Yes to LHS at Cawley**

Make your voice heard!
Send a text to **(978) 905-0663**
or
email us at citizensforcawley@gmail.com

តើលោកអ្នកចង់ឲ្យសាលាឡូវែលហាយស្គូល :
- ជាវិទ្យាល័យថ្មី និងទំនើប 100% រឺ?
- កាន់តែប្រសិទ្ធិភាពបំផុត សម្រាប់ការរៀនសូត្រដ៏ប្រសើររឺទេ?
- មានសុវត្ថិភាព និងគ្មានការរំខានដល់ការសិក្សារឺយ៉ាងណា?
- កាន់តែមានការចូលរួម និងមានការកំណត់ទីតាំងដែររឺទេ?

**និយាយថា យល់ព្រម ចំពោះសាលាឡូវែលហាយស្កូលនៅ** Cawley
ចូលរួមបញ្ចេញមតិយោបល់របស់លោកអ្នក!
សូមផ្ញើសារមកកាន់លេខ **(978) 905-0663**
រឺ
អ៊ីម៉េលមកយើងខ្ញុំតាមរយៈ: citizensforcawley@gmail.com

# លោក រ៉ាឌី ម៉ម ទៅទស្សនកិច្ចនៅកម្ពុជាម្តងទៀតជាផ្លូវការ

**ដោយខ្មែរផុសស.រ.អា.**

ទូរទស្សន៍កម្ពុជាបានធ្វើសេចក្តីរាយការណ៍ពីដំណាងរដ្ឋម៉ាសាឈូសិត សង្កាត់លេខ១៨ រ៉ាឌី ម៉ម បានទៅធ្វើទស្សនកិច្ច នៅកម្ពុជាកាលពីថ្ងៃទី៧មេសាឆ្នាំ២០១៧។ នេះគឺជាលើកទីពិហើយ ដែលលោក រ៉ាឌី ម៉ម អមដំណើរដោយ ខេវិន ខប្លីន ជំនួយការប្រធានសាលាក្រុងឡូវែលបាន ទៅធ្វើទស្សនកិច្ចជួបលោកទេសរដ្ឋមន្ត្រីក្រសួងកាបរទេស ប្រាក់ សុខុន នឹងមន្ត្រីក្រសួងការបរទេសជាច្រើនទៀត បន្ទាប់ពីលោកបានជាប់ឆ្នោតជាលើកទីពីរតំណាងឱ្យសង្កាត់លេខ១៨មក។

លោក រ៉ាឌី ម៉ម បានធ្វើការកត់សំគាល់ប្រាប់បណ្តាញព័ត៌មានជាអាទិ៍ថា"លោកបានឃើញប្រទេសកម្ពុជាមានការលូតលាស់ជាខ្លាំង..." ដែលនេះជាលើកទី២ដែរ ដែលប្រជាពលរដ្ឋដើមកំណើតខ្មែរនៅឯសហរដ្ឋអាមេរិកនឹងនៅប្រទេសសេរីឯទៀត មានការទិទៀន នឹងសំដែងការខកចិត្តជាខ្លាំង ចំពោះវត្តមានរបស់លោកដើម្បីទៅសំដែងការកាំទ្រសមាជិករដ្ឋាភិបាលភ្នំពេញនៅប្រទេសកម្ពុជា។

នៅតុកាហ្វេនាហាងភ្នំពេញទល់មុខហាងចាប់សរសៃរបស់លោក នាថ្ងៃសុក្រទី៧នេះបងប្អូន



លោក រ៉ាឌី ម៉ម តំណាងរដ្ឋសង្កាត់លេខ១៨ រដ្ឋម៉ាសាឈូសេត ជួបសម្តែងការគួរសមជាមួយលោកទេសរដ្ឋមន្ត្រីការបរទេស ប្រាក់ សុខុន

ខ្មែរមួយក្រុមឆ្ងលថា "សាលាក្រុងឡូវែលគួរពន្យល់ពលរដ្ឋខ្លួនពីប្រាក់ចំណាយរបស់លោក រ៉ាឌី ម៉ម នឹងលោក ខេវិន ខប្លីន សម្រាប់ធ្វើដំណើររបស់លោកទាំងពីរ តើមានប៉ះពាល់ដល់"លុយ-តាក់"ប្រជាពលរដ្ឋដែរឬទេ? ពីព្រោះគ្មាននរណាចង់ឱ្យលោកទាំង២នេះ ទៅជាតំណាងជនជាតិខ្មែរឡូវែលទៅជួបចរចារជាអ្វីនឹងរដ្ឋាភិបាលភ្នំពេញទេ!", នៅលើទំព័រហ្វេសប៊ុក នា២ថ្ងៃចុងក្រោយនេះ គ្មានឃើញព័ត៌មានសំដែងការកោតសសើរណាមួយចំពោះទស្សនៈកិច្ចលោក រ៉ាឌី ម៉ម នឹងលោកខេវិន ខប្លីន នៅកម្ពុជានោះទេ



មានតែជេរប្រទេចផ្តាសារថែមទៀតផង។

ការងារក្នុងសហគមន៍នៅមានច្រើនដែលត្រូវដោះស្រាយ ដូចជាចុងក្រោយនេះបញ្ហាប្តូរទីតាំងវិទ្យាល័យឡូវែលគ្មានដំណាងរាស្ត្រណាមកណែនាំសហគមន៍ខ្លួននោះទេ បែរជាតំណាងរដ្ឋខ្មែរ-អាមេរិកកាំងម្នាក់នេះទៅយកបញ្ហានៅកម្ពុជាជាសំខាន់ទៅវិញ ហើយបញ្ហានេះទៀត សោតវាផ្ទុយនឹងបំណងនៃមតិភាគច្រើន ថែមទៀតផង, គេថាសហគមន៍ខ្មែរចូលចិត្តតែបែកបាក់គ្នាលើកនេះជាគំរូមួយបង្ហាញថា "ថ្នាក់ដឹកនាំទៅដែលក្បត់នឹងបំណងរាស្ត្រមណ្ឌលរបស់ខ្លួន ហើយខំពន្យល់គេឯងថាខ្លួនធ្វើនោះត្រឹមត្រូវហើយ!"៕



## តមកពីទំព័រទី ០១ មហាសង្ក្រាន្តឆ្នាំថ្មី ឆ្នាំរកា...

១៣៧៩ នឹងចូលមកដល់នៅរយៈពេលដ៏ខ្លីខាងមុខនេះ ពោលនៅថ្ងៃសុក្រ ៣រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែ មេសា គ.ស. ២០១៧ វេលាម៉ោង០៣:១២នាទីទៀបភ្លឺ។

ដើម្បីចូលរួមអបអរដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ យើងខ្ញុំសូមលើកយកនូវមហាសង្ក្រាន្តឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ដែលដកស្រង់ចេញពីសៀវភៅមហាសង្ក្រាន្តរបស់លោក អ៊ឹម បុរិន្ទ




អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងគណៈកម្មការស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ និងប្រពៃណីទំនៀមទម្លាប់ខ្មែរ ជូនប្រិយមិត្តអ្នកអានដូចខាងក្រោមៈ

### សុភមស្តុ! វរមង្គលាជយាតិរេក

ព្រះពុទ្ធសករាជព្រះសាសនាអតិក្កន្តា កន្លងទៅហើយបាន២៥៦០ ត្រឹមថ្ងៃទី១៥ កើតខែពិសាខ លុះដល់ថ្ងៃ១រោច ខែពិសាខ ឆ្នាំរកា នព្វស័កតទៅ ចូលពុទ្ធសករាជ ២៥៦១។

តាមគណនាឆ្នាំរកាឥឡូវនេះសង្ក្រាន្តចូលមកនៅថ្ងៃសុក្រ ៣រោច ខែចេត្រ ត្រូវ នឹងថ្ងៃទី១៤ ខែមេសា គ.ស. ២០១៧ វេលាម៉ោង០៣:១២នាទី។ ពេលនោះ ព្រះអាទិត្យចេញពីមីនរាសីទៅឋិតនៅឯមេសរាសីតាមផ្លូវគោវិថី គឺជាផ្លូវកណ្តាល ទើបទេវធីតា មួយអង្គជា មគ្គនាយិកា ព្រះនាម "កិមិរាទេវី" ជាបុត្រីទី៦ នៃកបិលមហាព្រហ្មទ្រង់គង់នៅចាតុម្មហោរាធិការទ្រង់អម្ពរពណ៌សេតលម្អនៅព្រះ កាណ៌ ដោយបុប្ផ ចង្កុរណី អភរណៈ កែវបុស្ស រាគ័ម ភក្សាហារទញ្ញរង់ ចេក ណាំវ៉ា ព្រះហស្ត ស្តាំទ្រង់ ព្រះខ័ន្ធ ព្រហស្តឆ្វេងទ្រង់ពិណ ទ្រង់គង់ ផ្ទំបិទព្រះនេត្រលើខ្នង មហឹង្សា (ក្របី) ជា ពាហនៈ។

ទើបនាំអស់ទេវបុត្រទេវធីតា ទាំងមួយសែនកោដិហោះទៅកាន់ គុហាកែវធម្មមាលីនាទីភ្នំកៃលាស ខេត្តហិមពាន្ត ជាទីតំកល់ទុកនូវព្រះសិរសាកបិលមហាព្រហ្ម ដែលតំកល់លើពានមាសនាំមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុរាជ តាមផ្លូវព្រះអាទិត្យចរចំនួន៦០ នាទីទើបនាំយកទៅតម្កល់ទុកកន្លែងដើមវិញ ហើយប្រជុំទេវបុត្រទេវធីតា ទាំងមួយសែនកោដិចូលស្រង់ទឹក អនោតត្តមហាស្រះ ដែលមានទឹកហូរចេញពីបំពង់ថ្មកែវ ដែលជាមាត់គោ ឧសភរាជ ទាំង៧ត្រជាក់ក្សេមក្សាន្តព្រះរាជហឫទ័យ ហើយនាំគ្នាចូលទៅសមាទានសក្ការសីល ដោយសោមនស្សរីករាយគ្រប់ៗព្រះអង្គក្នុងភគវតីសភាសាលាដែលព្រះវិស្សកម្មទេវបុត្រនិមិត្តថ្វាយ ដើម្បីបន្ទោបង់អពមង្គលឱ្យជ្រះស្រឡះ ហើយចម្រើននូវសិរីសួរស្តី ជ័យមង្គល ជន្មាយុយឺនយូរដល់ទេវតា និងមនុស្សសត្វផងទាំង ឡាយ តាំងពីឆ្នាំថ្មីចូលមកនេះ បានទូលំទូលាយ សុខក្សេមក្សាន្តតរៀងទៅ។

* នៅថ្ងៃសុក្រ ៣រោចខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស.២០១៧ វេលាម៉ោង០៣:១២នាទីទៀបភ្លឺ ជាថ្ងៃចូលឆ្នាំរកា នព្វស័ក (ជាវារៈមហាសង្ក្រាន្ត)។

*ថ្ងៃសៅរ៍៤ រោចខែចេត្រត្រូវនឹងថ្ងៃទី១៥ ខែមេសា គ.ស២០១៦ ជាវារៈវ័នបត។

*ថ្ងៃអាទិត្រ៥រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៦ ខែមេសា គ.ស២០១៧ នៅវេលាម៉ោង០៦:៤៦ នាទី ៤៨វិនាទី ជាវារៈឡើងស័ក គម្រប់ជាសង្ក្រាន្ត

តទៅទំព័រទី ២១



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការធ្វើសវនកម្មគាំទ្របញ្ជីឈ្មោះបោះឆ្នោតថ្មី ប៉ុន្តែមន្ទិលនៅតែមាន

**ដោយ hannahhawkins និង វណ្ណ រឿន | ថ្ងៃពុធ ទី១២ខែមេសា ឆ្នាំ២០១៧**

ផ្ទុយពីបញ្ជីឈ្មោះបោះឆ្នោតអាណត្តិមុនៗ ដែលជាប្រភពមួយក្នុងចំណោមប្រភពធំៗនាំឱ្យមានការផ្ទុះកំហឹង និងភាពទោមនស្សបញ្ជីឈ្មោះបោះឆ្នោតថ្មីដែលបានបង្កើតឡើងសម្រាប់ការបោះឆ្នោតឃុំសង្កាត់នៅខែមិថុនាខាងមុខនេះបានឆ្លងផុតការធ្វើសវនកម្មហើយដោយទទួលបានលទ្ធផលដ៏ល្អប្រសើរ ខណៈអ្នកធ្វើអត្ថាធិប្បាយនៅតែមានមន្ទិលថា តើប្រទេសកម្ពុជាពិតជាអាចរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅថ្ងៃទី៤ ខែមិថុនាបានមែនឬយ៉ាងណា។

កាលពីល្ងាចមិញ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានចេញរបាយការណ៍ពេញលេញពាក់ព័ន្ធបញ្ជីឈ្មោះបោះឆ្នោតដែលធ្វើថ្មីទាំងស្រុងឡើងវិញ បន្ទាប់ពីគណៈកម្មាធិការនេះបានចេញរបាយការណ៍សង្ខេបមួយអំឡុងសន្និសីទកាសែតកាលពីសប្តាហ៍មុន។

របាយការណ៍របស់ខុមហ្វ្រែលមានខ្លឹមសារដូច្នេះថា "សវនកម្មនេះបានរកឃើញថា ភាពត្រឹមត្រូវ និងជឿជាក់លើគុណភាពបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦ មានភាពត្រឹមត្រូវ និងច្បាស់លាស់ បើប្រៀបធៀបជាមួយបញ្ជីឈ្មោះពីមុនៗ"។

ខុមហ្វ្រែលបានផ្ទៀងផ្ទាត់ឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតតាមរយៈការចុះស្ទាបស្ទង់មតិអ្នកបោះឆ្នោតពិតប្រាកដដោយផ្ទាល់។ គណៈកម្មាធិការនេះបានស្ទាបស្ទង់មតិអ្នកបោះឆ្នោតចំនួន២.៦៩០ នាក់នៅទូទាំងប្រទេសដើម្បីផ្ទៀងផ្ទាត់ព័ត៌មានលម្អិតរបស់ពួកទៅនឹងអ្វីដែលបានកត់ត្រាក្នុងបញ្ជីឈ្មោះបោះឆ្នោតថ្មី។

របាយការណ៍នេះបានលើកឡើងបន្តថា ៩៨ ភាគរយនៃឈ្មោះដែលត្រូវបានជ្រើសរើសចោះៗពីបញ្ជីឈ្មោះឌីជីថលថ្មីត្រូវបានរកឃើញថា ត្រឹមត្រូវ បើធៀបទៅនឹងបញ្ជីឈ្មោះមុនដែលមានភាពត្រឹមត្រូវត្រឹមតែ៨១ភាគរយនោះ។

របាយការណ៍នេះបានលើកឡើងថា មាន ៩៦,៨ភាគរយនៃទិន្នន័យដែលបានវិភាគបង្ហាញថា ឈ្មោះអ្នកបោះឆ្នោត គឺត្រឹមត្រូវ៩៩,៧ភាគរយបង្ហាញអំពីភាពត្រឹមត្រូវនៃព័ត៌មានអំពីភេទរបស់អ្នកចុះឈ្មោះបោះឆ្នោត៩៦ភាគរយបង្ហាញថា ថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតត្រឹមត្រូវ និង៩៧ភាគរយជាកម្រិតនៃភាពត្រឹមត្រូវនៃព័ត៌មានអាសយដ្ឋានរបស់អ្នកផ្តល់ចម្លើយ។

សវនកម្មឆ្នាំ២០១៣ដែលធ្វើឡើងដោយអង្គការបោះឆ្នោតមិនមែនរដ្ឋាភិបាលចំនួនពីរផ្សេងទៀតបានរកឃើញថា មានឈ្មោះត្រឹមតែ៨៧,៣ ភាគរយប៉ុណ្ណោះដែលត្រូវបានកត់ត្រាត្រឹមត្រូវនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតមុន រីឯថ្ងៃខែឆ្នាំកំណើតវិញកត់ត្រាត្រឹមត្រូវបានត្រឹមតែ៦៣,៧ភាគរយប៉ុណ្ណោះ។

របាយការណ៍របស់ខុមហ្វ្រែលបានបន្តថា "គួរបញ្ជាក់ផងដែរថា ទិន្នន័យបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវបានកត់ត្រាទុកជាមួយនឹងកម្រិតនៃភាពត្រឹមត្រូវខ្ពស់ដែលមានកម្រិតច្រើនជាង ៩៣ភាគរយចំពោះអ្នកផ្តល់ចម្លើយម្នាក់ៗ"។

បញ្ជីឈ្មោះនេះដែលពីមុនកត់ត្រាដោយដៃនោះ ត្រូវបានរៀបចំឡើងវិញទាំងស្រុងកាលពីឆ្នាំមុន បន្ទាប់ពីមានសេចក្តីរាយការណ៍អំពីភាពមិនប្រកតីដែលធ្វើឱ្យផ្ទុះការតវ៉ាទ្រង់ទ្រាយធំនៅក្នុងរាជធានីភ្នំពេញ ក្រោយការបោះឆ្នោតជាតិឆ្នាំ ២០១៣ដ៏ចម្រូងចម្រាសដែលគណបក្សសង្គ្រោះជាតិបានអះអាងថា ម្លេះខ្លួនឈ្នះគណបក្សប្រជាជនកម្ពុជាបាត់ទៅហើយ បើមិនមានការបន្លំឈ្មោះអ្នកបោះឆ្នោត។

យោងតាមរបាយការណ៍ឆ្នាំ២០១៣ចេញដោយខុមហ្វ្រែលស្តីពីការបោះឆ្នោតជាតិនៅក្នុងឆ្នាំនោះ មានអ្នកបោះឆ្នោតច្រើនរហូតដល់១,២៥ លាននាក់បានបាត់បង់សិទ្ធិបោះឆ្នោតដោយសារភាពមិនប្រក្រតីនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។ អ្នកបោះឆ្នោតមួយចំនួនរអ៊ូរទាំចំពោះព័ត៌មានលម្អិតដែលកត់ត្រាមិនបានត្រឹមត្រូវ រីឯអ្នកអង្កេតការណ៍បោះឆ្នោតវិញក៏បានលើកឡើងអំពី "អ្នកបោះឆ្នោតខ្មោច" ដែលឈ្មោះរបស់ពួកគេជាន់គ្នា ឬផ្ទៀងផ្ទាត់មិនត្រូវទាល់តែសោះ។




# AUDIT GIVES THUMBS-UP TO VOTER LIST; DOUBTS LINGER

**by Hannah Hawkins and Van Roeun | April 12, 2017**

Rectifying one of the greatest sources of outrage and discontent surrounding previous elections, the voter list compiled for upcoming commune elections has passed an audit with flying colors, though commentators remain skeptical as to whether the country will actually witness free and fair elections on June 4.

The Committee for Free and Fair Elections in Cambodia (Comfrel) on Tuesday published its full report on the completely remade voter list, following the NGO coalition's release of a summary at a news conference last week.

"This audit found that there are significant improvements on the quality of the 2016 voter list in its completeness, currency, and accuracy compared with the previous voter list," Comfrel's report says.

Comfrel verified names on the registration list by tracking down actual voters. It surveyed 2,690 voters around the country to check their details against what had been recorded on the new electoral rolls.

Ninety-eight percent of the names randomly selected from the new digitized voter list were found to be legitimate, compared to just 81 percent on the previous list, the report says.

Surveyed voters' names had also been recorded accurately 96.8 percent of the time, their genders 99.7 percent of the time, dates of birth 96 percent and addresses 97 percent, it says.

A 2013 audit by two other election NGOs found that only 87.3 percent of names were recorded properly in the previous list, while date of birth was recorded accurately just 63.7 percent of the time.

"It is notable that voter registration data was captured with a high degree of accuracy with more than 95 percent in each case," Comfrel's report says.

The list-which had previously been compiled by hand-was entirely redone last year after reported irregularities sparked massive protests in Phnom Penh in the wake of the disputed 2013 national election, which the opposition CNRP has claimed it narrowly lost to the CPP amid voter fraud.

According to a 2013 report by Comfrel into that year's national elections, as many as 1.25 million voters were disenfranchised due to irregularities in the voter list. Some voters complained of incorrectly recorded details, while election observers also cited "ghost voters," whose names had been duplicated or could not be verified at all.

Following a standoff between the CNRP and CPP after the vote, election laws were amended and a new elections body formed. The National Election Committee (NEC) has four members appointed from each party, as well as a bipartisan ninth member.

The registration process was also given a substantial upgrade and transitioned from paper to digital. Cambodians registered their details with NEC officials, rather than commune police officers, this time around.

Comfrel senior program coordinator Kim Chhorn said the positive survey results were due to a modernized registration process, which was digitized with the backing of Japan and the E.U.

Sam Kuntheamy, executive director of Neutral and Impartial Committee for Free and Fair Elections in Cambodia (Nicfec), which helped Comfrel conduct the study, said the fact that specially trained NEC officials-rather than commune police-accepted voter details had also improved accuracy.

Compared to the old list, "very few mistakes" were found, he said. "Last time, many people complained about the registration."

NEC spokesman Hang Puthea said irregularities had not appeared this time.

"No duplicate names exist. The list is accurate, because of electronic biometric registration," he said. "It is better than the previous ones."

Mr. Puthea said his biggest concern about the upcoming June commune elections was whether people would have the required documents for voting on Election Day.

"We are worried that some people who lose their IDs and do not ask for confirmation of their IDs…will not be allowed to vote," he said.

CPP spokesman SokEysan said the voter list was as good as anyone could have hoped.

"This showcases that NEC has done a good job. It is NEC's success. I think 98 percent is considered as perfect," Mr. Eysan said. "We have more accuracy than the previous ones thanks to advanced technology."

Political analyst Cham Bunthet, who is an adviser to the opposition Grassroots Democracy Party, said it was still hard to believe Cambodia would actually witness free and fair elections, considering its history.

"Actually, the election in Cambodia has never been free and fair, maybe since 1993," Mr. Bunthet said, referring to the country's first elections following decades of war that were set up by the U.N.

"We're not that lucky in Cambodia for the last three or four other elections…. I don't expect we will have free and fair elections in 2017 or 2018."

Mr. Bunthet said the voter list may no longer be an issue, but that was not enough.

"In order to compete fairly, you need to have a free environment where you can advocate freely, appeal to voters, and voters can hear the voices of parties, and there's no potential threat, blocking or pressuring [parties] over particular issues."

Even with a pristine voter list, the ruling CPP likely had tricks left up its sleeve to turn the elections in its favor, Mr. Bunthet said.

"Oh yes," he said. "I think they're very smart."

hawkins@cambodiadaily.com, roeun @cambodiadaily.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# គ.ជ.ប.ព្រមានមិនឱ្យមានការស្ទង់មតិនៅមុនថ្ងៃបោះឆ្នោត

**ដោយ បែន សុខហ៊ាន និង Ben Paviour | ថ្ងៃច័ន្ទ ទី៣ ខែមេសា ឆ្នាំ២០១៧**

ស្ថាប័នបោះឆ្នោតកំពូលក្នុងប្រទេសកម្ពុជានឹងចាត់វិធានការប្រឆាំងក្រុមណាដែលធ្វើ ឬផ្សព្វផ្សាយលទ្ធផលស្ទង់មតិ២សប្តាហ៍មុនការបោះឆ្នោតឃុំ សង្កាត់ នៅថ្ងៃទី៤ ខែមិថុនា ដោយព្រមានថា ការស្ទង់មតិនេះអាចនាំឱ្យមានអស្ថិរភាពសង្គមនេះបើតាមអ្នកនាំពាក្យរបស់ខ្លួន។

យោងតាមលោក ហង្ស ពុទ្ធា អ្នកនាំពាក្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) បានឱ្យដឹងថា បម្រាមលើការស្ទង់មតិនេះនឹងចាប់ផ្តើមនៅថ្ងៃទី២០ ខែឧសភា ហើយបន្តរហូតមកដល់ថ្ងៃបោះឆ្នោត ដែលលោកបានប្រដូចការស្ទង់មតិនេះទៅនឹង"ឧបាយកលអាក្រក់"។

លោកបានថ្លែងកាលពីម្សិលមិញថា "ទោះបីជាអ្នកមានបំណងប្រើប្រាស់ឧបាយកលយ៉ាងណា គ.ជ.ប. រៀបចំមិនឱ្យមានព្រឹត្តិការណ៍ហ្នឹងកើតឡើងមុនថ្ងៃបោះឆ្នោតបានទេ"។

លោកបានបន្ថែមថា "បើនៅតែមិនអនុវត្ត (សេចក្តីណែនាំរបស់គ.ជ.ប.) គ.ជ.ប.នឹងផ្ទៀងផ្ទាត់ទៅលើច្បាប់បទបញ្ជានៃការបោះឆ្នោត ហើយនឹងចាត់វិធានការទៅតាមផ្លូវច្បាប់"។

ការអត្ថាធិប្បាយរបស់លោក ហង្ស ពុទ្ធា បានកើតមានឡើងបន្ទាប់ពីអត្ថបទថ្ងៃទី២៤ ខែមីនា មួយចុះផ្សាយតាមគេហទំព័រព័ត៌មានក្នុងស្រុក VoD Hot News ដែលបង្ហោះតាមទំព័រហ្វេសប៊ុករបស់ យឿង សុធារ៉ា មន្ត្រីផ្នែកច្បាប់ និងឃ្លាំមើលនៅគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(ខុមហ្វ្រែល)។

លោក យឿង សុធារ៉ា បានអះអាងថា លោកបានឃើញលទ្ធផលនៃការស្ទង់មតិថ្មីមួយក្នុងឃុំសង្កាត់ ជាង១.000ដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលលោកបានបដិសេធមិនចេញឈ្មោះ និងដែលបានព្យាករថាគណបក្សប្រឆាំងនឹងឈ្នះយ៉ាងតិចក៏៦0ភាគរយក្នុងចំណោមអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់។

លោក យឿង សុធារ៉ា និងបុគ្គលិកខុមហ្វ្រែលមួយរូបទៀតមិនអាចទាក់ទងសុំការអត្ថាធិប្បាយបានទេកាលពីម្សិលមិញ។ ប៉ុន្តែលោក ហង្ស ពុទ្ធា បានមានប្រសាសន៍កាលពីម្សិលមិញថា គ.ជ.ប. គឺជាស្ថាប័នតែមួយគត់ដែលឯករាជ្យ និងមានសិទ្ធិចេញផ្សាយលទ្ធផលនៃការបោះឆ្នោត។ លោកបន្ថែមថា អ្នកបោះឆ្នោតនឹងមានការយល់ច្រឡំប្រសិនបើស្ថាប័នផ្សេងបង្ហាញទិន្នន័យស្ទង់មតិនៅមុនថ្ងៃបោះឆ្នោតនោះ។

លោកបានថ្លែងថា "ហើយព័ត៌មាន (ការស្ទង់មតិ) ដែលខុសពីអ្វីដែល គ.ជ.ប. ប្រកាសនោះគឺនាំឱ្យមានអស្ថិរភាពសង្គមក៏អាចថាបាន"។

លោក ហង្ស ពុទ្ធា បានលើកឡើងពីបម្រាមនោះ ដោយថ្លែងថា ការស្ទង់មតិបោះឆ្នោតនឹងគំរាមកំហែងដល់សិទ្ធិអំណាចរបស់គ.ជ.ប.ក្នុងការរៀបចំការបោះឆ្នោតប្រកបដោយការទុកចិត្ត និងតាមបែបលទ្ធិប្រជាធិបតេយ្យ។

លោកបានព្រមានថា "គ.ជ.ប.ទទួលខុសត្រូវរៀបចំការបោះឆ្នោតឱ្យមានភាពសេរី និងយុត្តិធមិអញ្ចឹងអ្វីដែលអាចប៉ះពាល់ដល់ភាពត្រឹមត្រូវ និងយុត្តិធមិគ.ជ.ប.ត្រូវតែចាត់វិធានការ"។

ទាំងច្បាប់បោះឆ្នោតឃុំសង្កាត់ និងច្បាប់គ្រប់គ្រងគ.ជ.ប.មិនបានលើកឡើងពីការស្ទង់មតិមុនការបោះឆ្នោតឡើយ។ មាត្រា៧២នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា"តម្រូវឱ្យមានការស្ទង់មតិ និងផ្សព្វផ្សាយព័ត៌មានអំពីលទ្ធផលស្ទង់មតិទាក់ទិនការបោះឆ្នោតដែលនឹងបញ្ចប់ក្នុងរយៈពេល៧ថ្ងៃនៅមុនថ្ងៃបោះឆ្នោត"។

នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ក្រសួងព័ត៌មានបានចេញគោលការណ៍ហាមមិនឱ្យប្រព័ន្ធផ្សព្វផ្សាយបរទេសផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិសម្រាប់រយៈពេល៥ថ្ងៃមុនថ្ងៃបោះឆ្នោត។

លោក សំ គន្ធាមី នាយកប្រតិបត្តិគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិមិប្ញហៅកាត់ថា (និចហ្វិក) បានមានប្រសាសន៍ថា ក្រុមរបស់លោកបានសហការជាមួយអង្គការមួយចំនួនធ្វើការស្ទង់មតិក្នុងពេលកន្លងមកប៉ុន្តែនឹងមិនចូលរួមដូចមុនឡើយក្នុងការបោះឆ្នោតចុងក្រោយនេះ។ លោកបានថ្លែងថា "យើងមិនចង់ឱ្យមានបញ្ហាណាមួយជាមួយ គ.ជ.ប.ឡើយ"។

លោកបានថ្លែងថា លោកគិតថា បម្រាមប្រឆាំងនឹងការស្ទង់មតិនេះ គឺមិនត្រឹមត្រូវឡើយ។ ក្នុងប្រទេសប្រជាធិបតេយ្យជាច្រើន ពួកគេយល់ឃើញថាវាមានសារៈសំខាន់ក្នុងការធ្វើការស្ទង់មតិបោះឆ្នោតនេះ។ គ.ជ.ប. គួរបើកចិត្តឱ្យទូលាយ ហើយធ្វើឱ្យកាន់តែមានតម្លាភាព"៕ **សារុន**




# OPINION POLLS TO BE BANNED AHEAD OF ELECTION

**by Ben Sokhean and Ben Paviour | April 3, 2017**

Cambodia's top election body will take legal action against groups that conduct or publish opinion polls in the two weeks leading up to June 4 commune elections, its spokesman said on Sunday, warning that the surveys could lead to "social instability."

The ban on surveys will begin on May 20 and continue through the vote, according to National Election Committee (NEC) spokesman Hang Puthea, who likened the surveys to a "bad trick."

National Election Committee President SikBunhok, center, speaks at a news conference in Phnom Penh in January. (Siv Channa/The Cambodia Daily)

"If anyone tries to do a bad trick, the NEC will absolutely not let that happen before the election," he said on Sunday. "If you do not implement the NEC's instruction, we will check the law or any electoral provisions and then take legal action."

Mr. Puthea's comments followed a March 24 article published on local news website VOD Hot News citing a Facebook post by YoeurngSotheara, the law and monitoring officer at the Committee for Free and Fair Elections in Cambodia (Comfrel).

Mr. Sotheara claimed he had seen the results of a new poll of residents living in more than 1,000 communes conducted by an international NGO, which he declined to name, that predicted the opposition party would win at least 60 percent of commune council seats up for grabs.

Mr. Sotheara and other Comfrel staff could not be reached for comment on Sunday.

But Mr. Puthea said on Sunday the NEC is the only body that is both independent and authorized to release election results, adding that voters would get confused if other organizations put out polling data ahead of election day.

"Any survey that is unlike the results released by the NEC will cause social instability," he said.

Mr. Puthea justified the ban by saying opinion polls would threaten the NEC's mandate to organize credible, democratic elections.

"So the NEC will take action against whoever affects free and fair elections," he warned.

Neither the commune election law nor the laws governing the NEC appear to mention pre-election polling. Article 72 of the Law on the Election of Members of the National Assembly requires that "all surveys and dissemination of the survey findings related to the election shall come to an end 7 (seven) days before the polling day."

In the run-up to the 2013 national election, the Information Ministry issued guidelines forbidding foreign media from broadcasting the results of surveys for the five days leading up to election day.

Sam Kuntheamy, executive director of civil society group the Neutral and Impartial Committee for Free and Fair Elections in Cambodia, said his group had worked with organizations conducting surveys in the past, but would sit out the latest vote.

"We don't want any problems with the NEC," he said.

Mr. Kuntheamy said he thought the ban against surveys was misguided, however.

"In many democratic countries, they find it useful to conduct voter election surveys," he said.

"The NEC should open its mind and [be more] transparent."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ស្ថានទូតអាមេរិកៈ អង្គភាពកិច្ចការមនុស្សធម៌អាមេរិក ត្រូវបានបង្ខំឱ្យចេញពីកម្ពុជា

**ដោយ Michael Dickisonនិង សេក ឧត្តម | ថ្ងៃអង្គារ ទី៤ខែមេសា ឆ្នាំ២០១៧**

ស្របពេលទំនាក់ទំនងកម្ពុជា-អាមេរិកកាន់តែមានភាពរកាំរកូសនឹងគ្នាស្ថានទូតអាមេរិកបានលើកឡើងកាលពីម្សិលមិញថា អង្គភាពកងទ័ពជើងទឹកដែលមានជំនាញខាងការងារមនុស្សធម៌ត្រូវបានបង្ខំឱ្យចាកចេញពីប្រទេសកម្ពុជាដោយធ្វើឱ្យប៉ះពាល់ដល់គម្រោងជួយសហគមន៍ក្នុងទំហំទឹកប្រាក់រាប់លានដុល្លារ ក្នុងនោះរួមមានដូចជាការសាងសង់មន្ទីរសម្ភពនិងបង្គន់អនាម័យតាមសាលារៀនជាដើម ។

ពិធីលាគ្នាសម្រាប់អង្គភាព "ឃ្មុំសមុទ្រ (Seabees)" ជាឈ្មោះយកចេញពីអក្សរកាត់ "C.B."ជាពាក្យកាត់សម្រាប់កងវិស្វកម្ម (Construction Battalion) នោះ ត្រូវបានធ្វើឡើងនៅស្ថានទូតអាមេរិកក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញសម្រាប់ក្រុមចុងក្រោយដែលមានគ្នា១៦នាក់របស់អង្គភាពនេះ នេះបើយោងតាមលោក ដេវីដ ចូសា (David Josar) អ្នកនាំពាក្យរងស្ថានទូតនេះ ។

លោក ដេវីដ ចូសា បានលើកឡើងក្នុងអ៊ីម៉ែលមួយថា "រាជរដ្ឋាភិបាលកម្ពុជាបានជូនដំណឹងជាផ្លូវការដល់ស្ថានទូតប្រាប់អំពីការសម្រេចចិត្តរបស់ខ្លួនកាលពីសប្តាហ៍មុននៅក្នុងការផ្អាកគ្មានកំណត់ពេលចំពោះបេសកកម្មរបស់កងវិស្វកម្មចល័តកងទ័ពជើងទឹកសហរដ្ឋអាមេរិកដែលបាននិងកំពុងអនុវត្តគម្រោងផ្តល់សេវានៅកម្ពុជាសម្រាប់សហគមន៍នៅតាមតំបន់ដែលគ្មានសេវាគ្រប់គ្រាន់ចាប់តាំងពីឆ្នាំ២០០៨មក" ។

កងទ័ពសហរដ្ឋអាមេរិក ត្រូវបានបដិសេធមិនឱ្យចូលមកក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះក្នុងនោះរួមមានទាំងការលុបចោលសមយុទ្ធរួមគ្នាសំខាន់ៗផងដែរ ។

សមយុទ្ធ "ឆ្មាំអង្គរ (Angkor Sentinel)" ប្រចាំឆ្នាំជាមួយកងទ័ពសហរដ្ឋអាមេរិកត្រូវបានផ្អាកកាលពីខែមករាសម្រាប់យ៉ាងយោចណាស់ឆ្នាំនេះ និងឆ្នាំបន្ទាប់ រីឯការហ្វឹកហ្វឺន "ការ៉ាត់" ជាមួយកងទ័ពជើងទឹកសហរដ្ឋអាមេរិកក៏ត្រូវបានលុបចោលផងដែរ ដោយរដ្ឋាភិបាលកម្ពុជាពន្យល់ថា ខ្លួនត្រូវការឱ្យកងទ័ពរបស់ខ្លួនផ្តោតលើបញ្ហាសន្តិសុខសម្រាប់ការបោះឆ្នោតនាពេលខាងមុខ ។

ចំណាត់ការនេះបង្ហាញថា កម្ពុជាកំពុងតែប្តូរជំហរគាំទ្ររបស់ខ្លួនពីសម្ពន្ធមិត្តលោកខាងលិចជាយូរមកហើយ ដោយងាកទៅរកប្រទេសចិនដែលផ្តល់ជំនួយ និងសម្ភារយោធាយ៉ាងច្រើនមកឱ្យកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយមិនខ្វល់ថា កម្ពុជានៅបន្តមានការរំលោភបំពានសិទ្ធិមនុស្ស ឬលទ្ធិប្រជាធិបតេយ្យនោះឡើយ ។ កាលពីខែធ្នូ"លំហាត់នាគមាស២០១៦ (Golden



សមាជិកកងវិស្វកម្មចល័តកងទ័ពជើងទឹកសហរដ្ឋអាមេរិកដែលគេហៅថា "ឃ្មុំសមុទ្រ" ចាប់ដៃជាមួយភាគីកម្ពុជាអំឡុងពិធីលាគ្នានៅស្ថានទូតអាមេរិក កាលពីម្សិលមិញក្នុងរូបភាពថតចេញពីវីដេអូដែលបង្ហោះក្នុងទំព័រហ្វេសប៊ុករបស់ស្ថានទូតនេះ ។ ហ្វេសប៊ុក

Dragon 2016)" រយៈពេល៩ថ្ងៃរវាងកងទ័ពកម្ពុជា និងកងទ័ពចិនមានទាហាន១.០០០នាក់បានចូលរួម ។

លោក ដេវីដ ចូសា បានលើកឡើងទៀតថា អង្គភាពឃ្មុំសមុទ្របានបញ្ចប់គម្រោងសាងសង់ក្នុងទំហំទឹកប្រាក់ជាង៥លានដុល្លារនៅក្នុងខេត្តចំនួន១១ក្នុងរយៈពេលជិត១ទសវត្សរ៍កន្លងមកនេះក្នុងនោះរួមមានដូចជាការកែលម្អមន្ទីរពេទ្យ ការជីកអណ្តូងទឹក និងបានធ្វើការជាមួយកងយោធពលខេមរភូមិន្ទ និងសហគមន៍មូលដ្ឋានជាដើម ។

លោកបានមានប្រសាសន៍ថា "ការសម្រេចរបស់រដ្ឋាភិបាលធ្វើឱ្យមានការលុបចោលគម្រោងដែលគ្រោងចំណាយទឹកប្រាក់៨០០.០០០ដុល្លារនៅក្នុងខេត្តចំនួន៨" ។ លោកបានពន្យល់ថា អង្គភាពនេះគ្រោងសាងសង់មន្ទីរសម្ភពចំនួន២ខ្នង និងបង្គន់អនាម័យចំនួន៦សម្រាប់សាលារៀន នៅក្នុងឆ្នាំនេះដោយគ្រោងចំណាយទឹកប្រាក់២៦៥.០០០ដុល្លារ ។

លោក ដេវីដ ចូសា បានថ្លែងថា "រដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ហេតុផលសម្រាប់ការសម្រេចរបស់ខ្លួននោះឡើយ ។ សូមអ្នកទៅសុំការពន្យល់ពីរដ្ឋាភិបាលទៅ" ។

**តទៅទំព័រទី១៣**

# US NAVAL AID UNIT PUSHED OUT, EMBASSY SAYS

**by Michael Dickison and Sek Odom | April 4, 2017**

Amid a widening gulf in U.S.-Cambodia relations, the U.S. Embassy said on Monday that a Navy unit specializing in humanitarian work had been forced to leave the country, imperiling hundreds of thousands of dollars worth of community projects, including the construction of maternity wards and school bathrooms.

A farewell ceremony for the "Seabees" unit-a name derived from "C.B.," short for Construction Battalion -was held at the U.S. Embassy in Phnom Penh on Monday for the group's final 16-person cohort, said David Josar, the embassy's deputy spokesman.

"The Royal Government of Cambodia officially notified the Embassy of its decision last week to postpone indefinitely the mission of the U.S. Navy Mobile Construction Battalion, which has been carrying out community service projects in underserved areas of Cambodia since 2008," Mr. Josar said in an email.

The U.S. military has been increasingly shut out of Cambodia over the past several months, including the cancellation of major joint exercises.

The annual "Angkor Sentinel" exercises with the U.S. Army were suspended in January until at least 2019, while "Carat" drills with the U.S. Navy were also dropped. The Cambodian government justified the change by saying it needed to focus its forces on security for the upcoming elections.

The moves have been widely interpreted as Cambodia shifting its allegiances from traditional Western allies toward China, which has showered Cambodia with aid and military equipment in recent years and does not demand that Cambodia uphold human rights or democracy. In December, a nine-day joint Chinese-Cambodian military exercise, "Golden Dragon 2016," marshalled 1,000 soldiers.

Mr. Josar said the Seabees had completed more than $5 million in construction projects in 11 provinces over nearly a decade, including hospital improvements and water wells, and had worked with the Royal Cambodian Armed Forces and local communities.

"The government's decision cancels more than $800,000 in planned projects in eight provinces," he said, explaining that the unit had been scheduled to build six school bathroom facilities and two maternity wards this year at a cost of $265,000.

"The Cambodian government did not offer a reason for their decision. We refer you to the government for an explanation," Mr. Josar said.

Defense Ministry spokesman Chhum Socheat, however, said he was unaware of the Seabees' expulsion, and Navy Commander Tea Vinh said the U.S. unit was merely taking a hiatus.

"They are stopping the projects. Now they're going back to their country for vacation," he said. "They'll still help us to build navy offices or schools."

NemSowath, director-general of the Defense Ministry's department of policy and foreign affairs, said he did not know about any recent communications with the U.S. Embassy regarding the Seabees.

John Blaxland, a professor of international security at Australian National University, said Cambodia was at the vanguard of a "competitive game" being played out in various corners of Southeast Asia.

"Elsewhere, there is an awareness that conceding too much to one side, China, narrows strategic options further down the track," Mr. Blaxland said in an email.

"It is with this in mind that Cambodia's neighbours in ASEAN remain eager to keep the US military engaged, while at the same time being wary of being too outspokenly sympathetic or pro US in their pronouncements and actions."

ឌី ខេមបូឌា ដេលី The Cambodia Daily
ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

# ក្រសួងព័ត៌មាន និងអ្នក កាសែតកម្ពុជាពង្រឹង ទំនាក់ទំនងជាមួយប្រទេសចិន

**ដោយ អួន ភាព | ថ្ងៃអង្គារ ទី១១ ខែមេសា ឆ្នាំ២០១៧**

មន្ត្រីក្រសួងមហាផ្ទៃ និងអ្នកកាសែតកម្ពុជាដែលមានសម្ព័ន្ធភាពជាមួយរដ្ឋាភិបាលនឹងទទួលបានវគ្គបណ្តុះបណ្តាលពីសមភាគីចិន ហើយនឹងធ្វើដំណើរទៅបំពេញទស្សនកិច្ចក្នុងប្រទេសនេះក្រោមកិច្ចព្រមព្រៀងថ្មីដែលប្រទេសទាំងពីរបានចុះហត្ថលេខាកាលពីម្សិលមិញ។

អ្នកកាសែត និងមន្ត្រីនឹងត្រូវផ្តល់ឱ្យនូវជំនាញរាយការណ៍ និងវគ្គបណ្តុះបណ្តាលបច្ចេកទេសនៅក្នុងប្រទេសចិនដែលជាប់លំដាប់ថ្នាក់ជិតបាតតារាងនៃសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០១៦របស់អ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Without Borders) ដែលដាក់ចំណាត់ថ្នាក់ឱ្យប្រទេសចំនួន១៨១ នេះបើយោងតាមអនុស្សរណៈនៃការយោគយល់គ្នាដែលត្រូវបានចុះហត្ថលេខាដោយលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោក ជាំង ជាស៊ី (Jiang Jieshi) រដ្ឋមន្ត្រីក្រសួងព័ត៌មានចិន។

លោក អ៊ុក គីមសេង អ្នកនាំពាក្យក្រសួងនេះបានលើកឡើងថា ប្រទេសចិន "បានសន្យារធ្វើអ្វីៗគ្រប់យ៉ាងក្នុងគោលបំណងរៀបចំកម្មវិធីសិក្សាសម្រាប់អ្នកជំនាញកម្ពុជា"។ លោកបានបន្ថែមថា កម្មវិធីនេះនឹងបើកចំហរសម្រាប់ទាំងបុគ្គលិកវិស័យឯកជន និងរដ្ឋ។

រដ្ឋាភិបាលក្រុងប៉េកាំងនឹងផ្តល់មូលនិធិ និងបច្ចេកវិទ្យាសម្រាប់កម្មវិធីផ្លាស់ប្តូរគ្នាទៅវិញទៅមកនេះដោយបន្តដើរតួនាទីក្នុងពេលចុប្បន្នរបស់ខ្លួន ក្នុងនាមជាម្ចាស់ជំនួយធំបំផុតរបស់កម្ពុជា។ ការចំណាយលើកម្មវិធីនេះមិនត្រូវបានបង្ហាញនោះឡើយ។

លោក អ៊ុក គីមសេង បានលើកឡើងទៀតថា មន្ត្រី និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយចិនក៏នឹងមកបំពេញទស្សនកិច្ចនៅក្រសួងព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយកម្ពុជាផងដែរ។

លោកបានថ្លែងថា "ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកផ្តោតលើព័ត៌មាននយោបាយ សេដ្ឋកិច្ចសង្គម វប្បធម៌ និងទេសចរណ៍ហើយ



លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានធ្វើកាយវិការអំឡុងជំនួបជាមួយសមភាគីចិននៅរាជធានីភ្នំពេញ កាលពីម្សិលមិញ។ រូបថត: ស៊ីវ ចាន់ណា,ឌី ខេមបូឌា ដេលី

វានឹងជួយយើងឱ្យដឹងថា អ្វីទៅដែលយើងមានរួមគ្នា"។

សេចក្តីប្រកាសនេះធ្វើឡើងក្រោយវេទិកាមួយដែលរៀបចំធ្វើឡើងកាលពីខែតុលាដោយមន្ត្រីឃោសនាការជាន់ខ្ពស់ម្នាក់នៅក្នុងគណបក្សកុម្មុយនិស្តចិន ដែលបានយកវេទិកានេះអំពាវនាវស្នើសុំឱ្យមានការបង្កើនការសហការគ្នា និងចែករំលែកព័ត៌មានរវាងប្រព័ន្ធផ្សព្វផ្សាយកម្ពុជា និងប្រព័ន្ធផ្សព្វផ្សាយរបស់ចិន។

ទូរទស្សន៍ វិទ្យុ និងកាសែតផ្សាយជាភាសាខ្មែរនៅកម្ពុជាភាគច្រើនគ្រប់គ្រងដោយរដ្ឋ

**តទៅទំព័រទី ១៥**

Continued from page 01

## MINISTRY, CAMBODIAN JOURNALISTS ...

Journalists and officials will be offered specialized reporting and technical training in China-which ranked near the bottom of the Reporters Without Borders' 2016 World Press Freedom Index of 181 countries-according to the memorandum of understanding inked by Information Minister Khieu Kanharith and his Chinese counterpart Jiang Jieshi.

China "promised to do everything out of a desire to prepare a program of study for Cambodian experts," said ministry spokesman Ouk Kimseng.

The program will be open to private sector and state employees, he added.

Beijing will provide funding and technology for the exchange program, continuing its recent role as Cambodia's largest donor. The cost of the program was not disclosed.

Chinese officials and media employees will also visit the Information Ministry and Cambodian media outlets, Mr. Kimseng said.

"The exchange of information focuses on political information, socioeconomics, culture and tourism, and will help us understand what we have in common," he said.

The announcement follows a forum hosted in October by a senior propaganda officer for the Communist Party of China, who used the platform to call for increased collaboration and sharing of news between Cambodian and Chinese media.

Cambodia's Khmer-language television, radio and newspapers are largely operated by the state or owners friendly to the CPP, according to research by the Cambodian Center for Independent Media and Reporters Without Borders.

But with the internet, and Facebook in particular, eclipsing TV as Cambodians' top news source, according to an Asia Foundation survey last year, the Cambodian media landscape remains diverse compared to China's.

"As well as building a Great Firewall to monitor and control blogs and social networks, the Communist Party exercises total control over China's many media outlets," Reporters Without Borders said on its website.

Political analyst Cham Bunthet said he was not surprised to see the Sino-Cambodian friendship stretch to media, with state-affiliated outlets in both countries pumping out sanctioned news.

"They have the same problems," Mr. Bunthet said on Monday. "There are a lot of terrible things that haven't been seen in the newspapers, television or radio. That's the nature of media in Asia."

តមកពីទំព័រទី ១២

## ស្ថានទូតអាមេរិកៈ អង្គភាពកិច្ចការ...

ទោះជាយ៉ាងណាលោក ឈុំ សុជាតិ អ្នកនាំពាក្យក្រសួងការពារជាតិបានលើកឡើងថា លោកមិនដឹងអំពីការបណ្តេញអង្គភាពឃ្មុំសមុទ្រចេញនោះឡើយ ហើយលោក ទៀ វិញ មេបញ្ជាការកងទ័ពជើងទឹកបានលើកឡើងថា អង្គភាពរបស់សហរដ្ឋអាមេរិកមួយនេះគ្រាន់តែឈប់សម្រាកមួយរយៈប៉ុណ្ណោះ។

លោកបានមានប្រសាសន៍ថា "ពួកគេផ្អាកគម្រោង។ ឥឡូវនេះពួកគេត្រឡប់ទៅប្រទេសរបស់ពួកគេវិញសម្រាប់វិស្សមកាល"។ លោកបាន បន្ថែមថា "ពួកគេនៅតែជួយយើងកសាងការិយាល័យកងទ័ពជើងទឹក ឬសាលារៀនដដែល"។

លោក នឹម សូវ៉ាត អគ្គនាយកនៃអគ្គ-នាយកដ្ឋានគោលនយោបាយ និងកិច្ចការបរទេសនៅក្រសួងការពារជាតិបានលើកឡើងថា លោកមិនដឹងទេ អំពីទំនាក់ទំនងណាមួយក្នុងពេលថ្មីៗជាមួយស្ថានទូតអាមេរិកពាក់ព័ន្ធនឹងអង្គភាពឃ្មុំសមុទ្រនេះ។

លោក ចន ប្លាកស៍ឡេន (John Blaxland) សាស្ត្រាចារ្យផ្នែកសន្តិសុខជាតិនៅសាកលវិទ្យាល័យជាតិអូស្ត្រាលី (Australian National University) បានលើកឡើងថា កម្ពុជាគឺជាផ្នែកមួយនៃ "ល្បែងដ៏ប្រកួតប្រជែង" ដែលកំពុងត្រូវបានលេងនៅក្នុងតំបន់ផ្សេងៗនៅអាស៊ីអាគ្នេយ៍។

លោកបានលើកឡើងក្នុងអ៊ីម៉ែលមួយថា "គេដឹងថា រដ្ឋាភិបាលផ្សេង បើងាកទៅរកចិនខ្លាំងពេកនឹងធ្វើឱ្យជម្រើសយុទ្ធសាស្ត្រនាពេលអនាគតរបស់ពួកគេមានកាន់តែតិចទៅៗ"។

លោកបានបន្ថែមថា "ពាក់ព័ន្ធបញ្ហាហ្នឹង គេដឹងថា ប្រទេសជិតខាងកម្ពុជានៅក្នុងតំបន់អាស៊ាននៅតែមានចិត្តចង់រក្សាទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក ហើយស្របពេលដំណាលគ្នានេះ ក៏មានការប្រុងប្រយ័ត្នខ្លាំងផងដែរក្នុងសំដែងការទោរទន់ឬការគាំទ្រសហរដ្ឋអាមេរិកខ្លាំងពេកពេលពួកគេធ្វើការលើកឡើងឬបញ្ចេញសកម្មភាពណាមួយ"៕ **ស៊ុយឈាង**

# ព័ត៌មានរបស់កាសែតខ្មែរផុសនឹងមាននៅវ៉ិបសាយសាកលវិទ្យាល័យ UMASS Lowell

**ឡូវែល-** សាកលវិទ្យាល័យម៉ាសាជូសេតឡូវែលហៅកាត់ UMASS Lowell នៅពេលនេះ បានកំពុងរៀបចំប្រមូលផ្តុំព័ត៌មានរាល់ការចុះផ្សាយរបស់កាសែតខ្មែរផុសដែលមានចាប់តាំងពីលេខចេញផ្សាយដំបូងរហូតមកដល់បច្ចុប្បន្នមិនត្រឹមតែសម្រាប់ជាជំនួយដល់សិស្សានុសិស្សក្នុងការសិក្សាស្រាវជ្រាវប៉ុណ្ណោះទេ










ថែមទាំងសម្រាប់សាធារណៈជនទូទៅផងដែរ។

សាកលវិទ្យាល័យ UMASS Lowell ដែលមានប្រវត្តិតាំងពីឆ្នាំ១៨៩៤ ហើយបច្ចុប្បន្ននេះបានក្លាយជាសាកលវិទ្យាល័យដ៏ល្បីមួយក្នុងចំណោមសាកលវិទ្យាល័យធំៗក្នុងរដ្ឋម៉ាសាជូសេត ដោយមានសិក្សានុសិស្សចុះឈ្មោះសិក្សាកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ ហើយក៏ជាសាកលវិទ្យាល័យដែលមានសិស្សមានសញ្ជាតិខ្មែរចូលសិក្សាច្រើនជាងគេផងដែរក្នុងតំបន់។ តាមរយៈកំណើននេះ UMASS Lowell បានបង្កើតមជ្ឈមណ្ឌលសេវាឌីជីថលមួយដែលជាកន្លែងសម្រាប់ជាជំនួយរាល់ព័ត៌មានជាឌីជីថល និងសាព័ត៌មានទាំអស់ដល់សិស្សានុសិស្ស។

លោក មេមីដ អាលី (Mehmed Ali) ជាជំនួយការនាយកផ្នែកគម្រោងគំនិតផ្តួចផ្តើមឌីជីថល (Digital Initiatives) បានប្រាប់កាសែតខ្មែរផុសតាមអ៊ីម៉េលឱ្យដឹងថា មជ្ឈមណ្ឌលសេវាឌីជីថលបានបង្កើតឡើងនៅឆ្នាំ២០១៦ និងមានតួនាទីជាច្រើនដូចជា រក្សាទុក និងកែសម្រួលព័ត៌មានឌីជីថល, ធ្វើឌីជីថលរាល់ឯកសារ, ខ្សែភាពយន្តនិងខ្សែអាត់សម្លេង, ការដាក់អក្សររត់នៅលើវីដេអូ, បង្កើតវ៉ិបសាយ និងឱ្យខ្ចីឧបករណ៍សម្រាប់ធ្វើភាពយន្ត។



លេខចេញផ្សាយដំបូងរបស់ខ្មែរផុសនៅ UMASS Lowell

លោកបន្តថា តាមរយៈជំនួយហិរញ្ញវត្ថុថ្មីៗនេះពីអង្គការ National Endowment of the Human និតិសេមជ្ឈមណ្ឌលសេវាឌីជីថលមានលទ្ធភាពធ្វើការរៀបចំរាល់ឯកសារដែលបានប្រមូលទាំងអស់ឱ្យបានរៀបរយ និងបានជួយដល់ការបង្កើតវិបសាយជាច្រើន ហើយបានដាក់បញ្ចូលឯកសារឌីជីថលប្រហែលជាង៥០,០០០រួចមកហើយ។

មជ្ឈមណ្ឌលនេះ ក៏បានកំពុងប្រមូលព័ត៌មានជាភាសាខ្មែរដែលចេញផ្សាយដោយកាសែតខ្មែរផុសស.រ.អាដោយសម្រួលទៅជាឯកសារឌីជីថល PDF សម្រាប់ផ្តល់ឱកាសដល់សិស្សានុសិស្សខ្មែរងាយស្រួលក្នុងកិច្ចការសិស្សាស្រាវជ្រាវ។ លោក អាលី បានបន្ថែមទៀតថា ការប្រមូលព័ត៌មានចុះផ្សាយដោយកាសែតខ្មែរផុសនេះបានចាប់ផ្តើមតាំងពីឆ្នាំ២០១៦ និងមិនទាន់បានបញ្ចប់រួចរាល់នៅឡើយនោះទេ នូវកំពុងដំណើរការបន្តនៅឡើយ ហើយគ្រោងនឹងដាក់បញ្ចូលក្នុងបណ្ណាល័យឯកសារតាមប្រព័ន្ធអេឡិចត្រូនិកឌីជីថលរបស់សាលានៅពេលបញ្ចប់ការប្រមូលនាពេលឆាប់ៗខាងមុខនេះ។ ដូច្នេះលោកអ្នកអាចនឹងទទួលបានព័ត៌មានរាល់ការចុះផ្សាយទាំងអស់របស់កាសែតខ្មែរផុសនាពេលខាងមុខដ៏ខ្លីដោយគ្រាន់តែចូលទៅកាន់វ៉ិបសាយរបស់សាកលវិទ្យាល័យ UMASS Lowell តាមរយៈ https://www.uml.edu/ បន្ទាប់មកចុចលើពាក្យ Academics រួមជ្រើសរើសយកពាក្យ Libraries នោះលោកអ្នកនឹងអាចស្វែងរកព័ត៌មានរបស់ខ្មែរផុសជាមិនខាន។

សូមបញ្ជាក់ថា ដោយបង្កើតនៅឆ្នាំ២០០៧ ក្នុងក្រុងហ្វីឡាដេលហ្វៀ ហើយបានផ្លាស់ប្តូរមកកាន់ក្រុងឡូវែលក្នុងឆ្នាំ ២០១០ កាសែតខ្មែរផុសស.រ.អា បានធ្វើការចុះផ្សាយបានចំនួន២២១ លេខរួមមកហើយរហូតមកដល់បច្ចុប្បន្ននេះ ដោយបាននាំមកនូវព័ត៌មានក្នុងស្រុក, ជាតិ និងអន្តរជាតិដល់សហគមន៍ដែលមិនបានទទួលព័ត៌មានជាភាសារបស់ពួកគេ តាមរយៈការបោះពុម្ពផ្សាយទាំងភាសា ខ្មែរ និងអង្គ្លេស៕

**ដោយ សុខារ័ត្ន កួយ**

សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
Cambodian American Biweekly Newspaper

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS

Contact us for the Advertising Opportunity!

978-677-7163 | http:/khmerpost.us

LW LICO WIRELESS, INC
boostmobile metroPCS T-Mobile
ទូរស័ព្ទ & កុំព្យូទ័រ
ជួសជុល • ទូរទាត់វិក័យប័ត្រ
មិនគិតថ្លៃការពិគ្រោះពិនិត្យ



បើកថ្ងៃចន្ទ – ថ្ងៃសៅរ៍ ១០ព្រឹក–៧យប់
978-735-4100
336 Westford Street, Unit1. Lowell, MA 01851

# សញ្ញាប័ត្រកោតសសើរប្រចាំជីវិតសម្រាប់សមាគមអង្គរ

## Life Time ArchievmentAward for Angkor Danse Troup

**ដោយខ្មែរផុសស.រ.អា.**

**ឡូវែល:** លោក ធីម ធូ ស្ថាបនិកនៃសមាគមអង្គរមានសេចក្តីរីករាយណាស់នៅពេលបានទទួលប័ណ្ណកោតសសើរប្រចាំជីវិត នាឱកាសខួបទី៣០នៃកំណើតសមាគមអង្គរនឹងបន្ទាប់ពីលោកបានចេញសម្តែងរបាំប្រជាប្រិយដោយខ្លួនឯងជាមួយនឹងនាថករ នាការីប្រមាណ៥០នាក់ រួមទាំងកូនស្រីលោកជាអតីតប្រធានប្រតិបត្តិនៅចំពោះមុខភ្ញៀវជាង៤០០នាក់ ដែលបានមកអបអរសាទររួចមក។

លោក ម៉ាយខិល ខនវេយ ប្រធានគណកម្មការនាយកសមាគមអង្គរបន្ទាប់ពីឡើងថ្លែងអំណរគុណភ្ញៀវកិត្តិយសទាំងអស់បានបើកកម្មវិធីសម្តែងដ៏ត្រចះត្រចង់ដោយនាំមកនូវរបាំជាមោទនភាពនៃសមាគមរបស់លោក គឺរបាំប្រពៃណីសម្តែងដោយទេពអប្សរសួគ៌ាមកថ្វាយព្រះពរដល់ព្រះរាជាខ្មែរដែលនៅពេលរាត្រីនោះតំណាងដោយភ្ញៀវកិត្តិយសដែលភាគច្រើនជាជនបរទេសមិនដែលបានឃើញរបាំដែលរៀបចំបានដោយកម្រនោះទេ។

រាត្រីទី៨មេសានេះ សមាគមអង្គរមិនត្រឹមតែទទួលរង្វាន់ទេ សមាជិកសមាជិការបានបង្ហាញនូវស្នាដៃថែរក្សាវប្បធម៌ជាតិក៏រីកខ្ពស់ដែលថ្វីត្បិតតែតួសសម្តែងជាកូនខ្មែរអាមេរិកាំងនៅឆ្ងាយពីស្រុកកំណើតភាសាខ្មែរក៏និយាយមិនសូវបានគ្រូបង្ហាត់ក៏មានចំនួនស្តួចស្តើងរបាំទាំងឡាយបានសម្តែងចេញមកដោយមិនបន្ថយគុណភាព តួសម្តែងរបាំចូលតួតាមសម្លេងភ្លេងប្រកបដោយភាពសោមនស្សជាភាពរីករាយដូចជានៅក្នុងភូមិដ្ឋាននាប្រទេសកម្ពុជាពិតៗមែនដែរ។ ប្តើមដោយរបាំប្រជាប្រិយដ៏ល្បីល្បាញប្រចាំតំបន់សៀមរាបរបាំត្រុដបានដឹកក្បាលដោយលោកគ្រូ





មាស គឹមហាន ដែលច្រៀងដេញឧបទ្រពចង្រៃចេញពីភូមិដ្ឋានដែលជាប្រពៃណីមួយនៃពិធីបុណ្យចូលឆ្នាំខ្មែរ។ របាំបន្តបន្ទាប់បានត្រូវនាំមកបង្ហាញពីសម្រស់នារីនឹងបុរសខ្មែរក្នុងរបាំប្រជាប្រិយដ៏មករបាំអង្រុតរាំបង្ហាញតួស្រីផ្តល់កិត្តយសឱ្យកញ្ញា លីនដា ស៊ូ ជាកូនស្រីលោក ធីម ធូ ដែលបានជូនដំណើរសមាគមអង្គរឱ្យបានរីកចំរើន រហូតមកដល់ពេលនេះ មុននឹងជំនួសដោយនាយិការថ្មីកញ្ញា ដារី ត្រាន នា២ឆ្នាំចុងក្រោយនេះ។

ជារាត្រីដ៏គួរឱ្យចងចាំ ដោយរបាំទេវៈជាប្រពៃណីប្រកបដោយសំលៀកបំពាក់គ្រឿងពណិមាសដ៏ភ្លឺជិញ្ចាច, ចងចាំដោយការសម្តែងចេញពីទឹកចិត្តរីករាយស្រស់បំព្រងនៃយុវនារីនឹងយុវជនដែលបានបូជាពេលវេលាចំពោះសិល្បៈខ្មែរ, ចងចាំដោយសហគមន៍បានទទួលស្គាល់ការតស៊ូដ៏ស្វិតស្វាញ ចំពោះការថែរក្សាវប្បធម៌ខ្មែររបស់ជនជាតិភាគតិចនៅឆ្ងាយពីប្រទេសកំណើត, ទាំងអស់នេះ ជាភាពអ៊ូអរយ៉ាងពេញទំហ៊ឹង នារាត្រីសមោសរ"សមាគមអង្គរ"នៅ១អាទិត្យមុនចូលឆ្នាំខ្មែរ។ រាត្រីដ៏រីករាយហ៊ោកញ្ជ្រៀវរហូតដល់ចប់ដោយមានលោក រ៉តនីយ អេលីយ៉ុត សមាជិកក្រុមប្រឹក្សាសាលាក្រុងឡើងមកបើក ចម្រៀងបទ"ឱបាត់ដំបង"ជាភាសាខ្មែរបានធ្វើឱ្យភ្ញៀវភ្ញាក់ផ្អើលជាខ្លាំង។

៣០ឆ្នាំក្រោយមកសហគមន៍ឡូវែលបានកំណត់ទទួលស្គាល់ថា"សមាគមអង្គរបាន



លោក ម៉ាយខិល ខនវេយ ប្រធានសមាគមអង្គរ







សែនមានន័យមកពីតំបន់ផ្សេងៗទៀតនៃប្រទេសកម្ពុជា ដូចជារបាំត្រឡោក របាំនារីជាជួរ បន្ទាប់



កសាងឡើងវិញនឹងថែរក្សាវប្បធម៌របស់ខ្មែរបានយ៉ាងប្រពៃទាំងបច្ចេកទេសនឹងទាំងវិញ្ញាណសិល្បៈ រហូតដល់អាចទៅជាក្រុមវិជ្ជាជីវៈបានទៀតផង ប្រសិនបើចង់" ក៏ប៉ុន្តែលោក ធិម ធូ បានបង្ហាញនូវការខ្វះខាតដែលមិនអនុញ្ញាតិឱ្យសមាគមរបស់លោកអាចក្លាយជាស្ថាប័នអប់រំសិល្បៈជាសាធារណទៅបានលោកបានសម្តែងថា "សមាគមអង្គរមិនអាចឆ្លងទៅបានទេ បើមិនអាចមានបុគ្គលិកពេញពេលសម្រាប់បើកសាលាបង្ហាត់បង្រៀនឱ្យបានច្រើនម៉ោងបានផងនោះ!"៕

---

## តមកទំព័រទី ១៣ ក្រសួងព័ត៌មាន និងអ្នកកាសែតកម្ពុជា...

ឬម្ចាស់ដែលមានសម្ព័ន្ធភាពជាមួយគណបក្ស ប្រជាជនកម្ពុជា នេះបើយោងតាមការសិក្សាស្រាវជ្រាវដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនិងអ្នកសារព័ត៌មានគ្មានព្រំដែន។

ប៉ុន្តែដោយសារអ៊ីនធឺណិត ជាពិសេសហ្វេសប៊ុក បានលប់លើទូរទស្សន៍ក្នុងនាមជាប្រភពព័ត៌មានសំខាន់បំផុតសម្រាប់ពលរដ្ឋខ្មែរនោះ បរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជានៅតែខុសគ្នាពីប្រទេសចិន នេះបើយោងតាមការស្ទាបស្ទង់មតិកាលពីឆ្នាំមុនរបស់មូលនិធិអាស៊ី (Asia Foundation)។

អ្នកយកព័ត៌មានរបស់មូលនិធីនេះបានលើកឡើងលើគេហទំព័រខ្លួនថា "ដោយបានបង្កើតប្រព័ន្ធគ្រប់គ្រងអ៊ីធឺណិត Great Firewall ដើម្បីតាមដាន និងគ្រប់គ្រងប្លក់ (blog) ព្រមទាំងបណ្តាញទំនាក់ទំនងសង្គមនោះ គណបក្សកុម្មុយនិស្តនេះគ្រប់គ្រងទាំងស្រុងលើប្រព័ន្ធផ្សព្វផ្សាយជាច្រើននៅក្នុងប្រទេសចិន"។

លោក ឆាំ ប៊ុនថេត អ្នកវិភាគនយោបាយបានលើកឡើងថា លោកមិនភ្ញាក់ផ្អើលទេ ដែលឃើញទំនាក់ទំនងមិត្តភាពកម្ពុជាចិនលាតសន្ធឹងរហូតដល់ប្រព័ន្ធផ្សព្វផ្សាយ។ ប្រព័ន្ធផ្សព្វផ្សាយដែលមានសម្ពន្ធភាពជាមួយរដ្ឋាភិបាលនៅក្នុងប្រទេសទាំងពីរនេះផ្សព្វផ្សាយតែព័ត៌មានដែលរងសម្ពាធពីរដ្ឋាភិបាលប៉ុណ្ណោះ។

លោកបានមានប្រសាសន៍កាលពីម្សិលមិញថា "ពួកគេមានបញ្ហាដូចគ្នា"។ លោកបានបន្ថែមថា "មានរឿងគួរឱ្យខ្លាចតក់ស្លុតជាច្រើនដែលមិនឃើញមាននៅក្នុងកាសែតទូរទស្សន៍ ឬវិទ្យុ"។ លោកបានបន្ថែមទៀតថា "នេះហើយជាសារធាតុរបស់ប្រព័ន្ធផ្សព្វផ្សាយនៅអាស៊ី"៕ **ស៊ុយឈាង**

# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

**តមកពីទំព័រទី ០៣** 

# បុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ...

ត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះដោះប្រស្នាមិនរួច"។ ឥន្ទ្រីញីសួរទៀតថា "ប្រស្នានោះដូចម្តេច?", ឥន្ទ្រីឈ្មោលឆ្លើយថា "ប្រស្នានោះមាន៣ខៈ ខទី១ ពេលព្រឹកសិរីសួស្តិ៍ឋិតនៅត្រង់ណា, "ខ" ទី២ ពេលថ្ងៃត្រង់សិរីសួស្តិ៍ឋិតនៅត្រង់ណា, និង "ខ" ទី៣ ពេលល្ងាចសិរីសួស្តិ៍ឋិតនៅត្រង់ណា"។

ឥន្ទ្រីញីសួរទៀត "ចុះសិរីសួស្តិ៍ទាំង៣ពេលនោះ ឋិតនៅត្រង់ណាទៅ?", ឥន្ទ្រីឈ្មោលឆ្លើយ "ខទី១ ពេលព្រឹកសិរីសួស្តិ៍ឋិតនៅលើមុខ ហេតុនោះ ទើបមនុស្សទាំងឡាយត្រូវយកទឹកទៅលប់មុខ, ខទី២ ថ្ងៃត្រង់សិរីឋិតនៅលើទ្រូង ហេតុនោះ ទើបមនុស្សត្រូវយកទឹកលាងទ្រូង, ខទី៣ ពេលល្ងាចសិរីស្ថិតនៅលើជើង ហេតុនេះ ទើបមនុស្សទាំងឡាយត្រូវយកទឹកលាងជើង"។

ធម្មបាលកុមារបានឮដូច្នេះ ក៏ត្រឡប់ទៅប្រាសាទវិញ។ ព្រឹកឡើងកបិលមហាព្រហ្ម ក៏ចុះមកសួរប្រស្នា ធម្មបាលកុមារក៏ឆ្លើយដោះត្រូវទាំង៣ខ។ តែមុននឹងកាត់ព្រះសិរសាដូចបានសន្យាគ្នា ព្រះកបិលមហាព្រហ្មបានហៅទេពធីតាទាំង៧អង្គ ដែលជាបាទបរិចារិកាព្រះឥន្ទ្រមកប្រាប់ថា "ឥឡូវបិតាត្រូវកាត់ព្រះសិរសា បូជាជូនធម្មបាលកុមារ តែបើដាក់ព្រះសិរសាបិតាទៅលើផែនដី នឹងកើតជាភ្លើងឆេះទាំងលោកធាតុ តែបើបោះទៅឰដ៏អាកាសភ្លៀងនឹងកើតគ្រោះរាំងស្ងួត ហើយបើចោលក្នុងមហាសមុទ្រ ទឹកនឹងរីងស្ងួតហួតអស់ ដូច្នេះសូមឱ្យបុត្រីទាំង៧អង្គ យកពានមកទទួលព្រះសិរសាបិតា"។ ថាហើយក៏កាត់ព្រះសិរសាហុចទៅឱ្យព្រះនាងទុង្សាទេវីជាបុត្រីច្បង។

ព្រះនាងទុង្សាទេវី ក៏យកពានទៅទទួលព្រះសិរសារបស់កបិលមហាព្រហ្ម ហើយដង្ហែរប្រទក្សិណជុំវិញភ្នំព្រះសុមេរុចំនួន៦០នាទី ហើយក៏អញ្ជើញទៅប្រតិស្ឋានទុកក្នុងមណ្ឌលក្នុងគុហាគន្ធមាលី នៃភ្នំកៃលាសបូជាគ្រឿងទិព្វផ្សេងៗ ព្រះវិស្សកម្មទេវបុត្រ ក៏និម្មិតរោងទិព្វដ៏ប្រណិតអមដោយកែវ៧ពណ៌ឈ្មោះថា "ភគវតីសភា" ឱ្យជាទីប្រជុំនៃទេវតា លុះដល់គម្រប់១ឆ្នាំជាសង្ក្រាន្តទេពធីតាទាំង៧អង្គ ក៏ផ្លាស់វេនគ្នាមកអញ្ជើញព្រះសិរសាកបិលមហាព្រហ្មចេញមកដង្ហែរប្រទក្សិណភ្នំព្រះសុមេររៀងរាល់១ឆ្នាំ ហើយត្រឡប់ទៅឋានទេវលោកវិញ។

* ឈ្មោះទេពធីតាមហាសង្ក្រាន្ត និងគ្រឿងអភរណៈ:

**១:** បើសង្ក្រាន្តជាថ្ងៃអាទិត្យ ទេពធីតាព្រះនាម "ព្រះនាងទុង្សាទេវី" សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ (គ្រឿងសោយ) អាវុធស្តាំកងចក្រ ឆ្វេងខ្យងស័ង្ខ ពាហនៈជាសត្វគ្រុឌ។ **២:** បើថ្ងៃចន្ទ ទេពធីតាព្រះនាម "ព្រះនាងគោរាគទេវី" សៀតផ្កាអង្គារបុស្ស គ្រឿងប្រដាប់កែវមុក្តា (គជខ្យង) ភក្សាហារប្រេង អាវុធស្តាំព្រះខ័ន្ឋ ឆ្វេងឈើច្រត់ ពាហនៈសត្វខ្លា។ **៣:** បើថ្ងៃអង្គារ ទេពធីតាព្រះនាម "ព្រះនាងរាគសាទេវី" សៀតផ្កាឈូក គ្រឿងប្រដាប់កែវមោរ៉ា (ត្បូងកែវរាងមូល) ភក្សាហារលោហិត អាវុធស្តាំត្រីសូល៍ (លំពែងផ្លែ៣) ឆ្វេងធ្នូ ពាហនៈសត្វសេះ។ **៤:** បើថ្ងៃពុធ ទេពធីតាព្រះនាម (ព្រះនាងមណ្ឌាទេវី) សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ពិទូរ្យ (កែវ) ភក្សាហារទឹកដោះសិប្បិ អាវុធស្តាំម្ជុល ឆ្វេងឈើច្រត់ ពាហនៈសត្វលា។ **៥:** បើថ្ងៃព្រហស្បតិ៍ ទេពធីតាព្រះនាម (ព្រះនាងកិរិណីទេវី) សៀតផ្កាមណ្ឌា គ្រឿងប្រដាប់កែវមរកត (ត្បូងពណ៌បៃតង) ភក្សាហារសណ្តែក ល្ង អាវុធស្តាំកង្វេរ (ដង្កាវដំរី) ឆ្វេងកាំភ្លើង ពាហនៈសត្វដំរី។ **៦:** បើថ្ងៃសុក្រ





ទេពធីតាព្រះនាម "ព្រះនាងកិមិរាទេវី" សៀតផ្កាចង្កុលនី គ្រឿងប្រដាប់បុស្សរាគ័ម ភក្សាហារចេកណាំវ៉ា អាវុធស្តាំព្រះខ័ន្ឋ ឆ្វេងពិណ ពាហនៈសត្វក្របី។ **៧:** បើថ្ងៃសៅរ៍ ទេពធីតាព្រះនាម "ព្រះនាងមហោទរាទេវី" សៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៏ ភក្សាហារសាច់ទ្រាយ អាវុធស្តាំកងចក្រ ឆ្វេងត្រីសូល៍ ពាហនៈសត្វក្ងោក។

* **ទំនៀមចូលឆ្នាំ:**

កាលដើមឡើយខ្មែរយើង តែងប្រារព្ធធ្វើបុណ្យចូលឆ្នាំក្នុងខែមិគសិរ ព្រោះគេកំណត់យកខែនេះ ជាខែដើមឆ្នាំ។ នាសម័យព្រេងនាយ ឆ្នាំនីមួយៗចែកជា៣រដូវតាមចន្ទគតិ មានហេមន្តរដូវ (រដូវទឹកសន្សើម), គិម្ហរដូវ (រដូវក្តៅ) និងវស្សានរដូវ (រដូវភ្លៀង)។ បុរាណាចារ្យលោកគិតថា ហេមន្តរដូវ ចាត់ទុកជារដូវដើមឆ្នាំ ប្រៀបបាននឹងពេលព្រឹកដែលផុតពីរាត្រី គឺជាពេលព្រឹក។ គិម្ហរដូវចាត់ទុកជាកណ្តាលឆ្នាំ ប្រៀបបានជាពេលថ្ងៃត្រង់។ វស្សានរដូវជារដូវមេឃងងឹតមានភ្លៀងផ្គរ ចាត់ទុកជាចុងឆ្នាំ ប្រៀបបាននឹងពេលព្រលប់។

ទំនៀមពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន៣ថ្ងៃ។ ថ្ងៃដំបូង ជាថ្ងៃមហាសង្ក្រាន្ត, ថ្ងៃទី២ ជាថ្ងៃវ័នបត និងថ្ងៃទី៣ ជាថ្ងៃឡើងស័ក។ ឯការកំណត់ ខែ-ថ្ងៃ-ម៉ោង-នាទី ដែលឆ្នាំចាស់ត្រូវផុតកំណត់ ហើយទេវតាឆ្នាំថ្មី ត្រូវចុះមកទទួលតំណែងពីទេវតាឆ្នាំចាស់នោះ គេអាចដឹងបានយ៉ាងទៀងទាត់ ដោយអាស្រ័យតាមក្បួនហោរាសាស្ត្របែបបុរាណ គឺក្បួនមហាសង្ក្រាន្តនេះឯង។

តើថ្ងៃចូលឆ្នាំថ្មីរបស់ខ្មែរយើង ត្រូវលើខែណា? ថ្ងៃណា? ចាប់ពីត្រឹមពីសម័យក្រុងអង្គរធំ (ប្រាសាទបាយ័ន) ឡើងទៅខ្មែរយើងប្រើឆ្នាំចន្ទគតិ (រាប់តាមដំណើរព្រះចន្ទ) ទើបកំណត់យកខែមិគសិរ (ជាខែទី១) ជាខែចូលឆ្នាំ ហើយខែកក្តិក ជាខែទី១២។

លុះក្រោយមក ទើបគេនិយមប្រើសុរិយគតិ (រាប់តាមដំណើរព្រះអាទិត្យ) ជាសំខាន់វិញ ហើយកំណត់ចូលឆ្នាំក្នុងខែចែត្រ (ខែទី៥) ដែលជាឆ្នាំកំណត់ព្រះអាទិត្យចូលកាន់មេរាសី ហើយថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី១៣ នៃខែមេសា (ចែត្រ) រៀងរាល់ឆ្នាំ ប៉ុន្តែយូរៗទៅមានភ្លាត់ម្តងៗ ចូលឆ្នាំក្នុងថ្ងៃទី១៤ ក៏មានខ្លះដែរ។ ការផ្លាស់ប្តូរនេះ ព្រោះបុព្វបុរសយើងយល់ឃើញថា នៅខែមិគសិរនេះ ប្រជាកសិករខ្មែររវល់មមាញឹកនឹងរបរកសិកម្មមានស្រែចម្ការជាដើម ទើបលោកលើកកំណត់ពេលចូលឆ្នាំមកធ្វើនៅខែចែត្រវិញ ដោយហេតុថា ខែចែត្រកិច្ចការច្រូតការបោកបែនបានចប់សព្វគ្រប់ ហើយប្រជាពលរដ្ឋខ្មែរទំនេរមានឱកាសធ្វើបុណ្យទានកម្សាន្តសប្បាយតាមប្រាថ្នា។

មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមសុរិយគតិ ហៅថា "សាមញ្ញសង្ក្រាន្ត" (ព្រះអាទិត្យដើរត្រង់ចំពីលើក្បាលជាសង្ក្រាន្ត)។ មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមចន្ទគតិ ហៅថា "អាយន្តសង្ក្រាន្ត" (ពេលដែលព្រះអាទិត្យ ដើរបញ្ឆៀងមិនត្រង់ចំលើក្បាល)។ គេនៅប្រើចន្ទគតិឯបគ្នានឹងសុរិយគតិដែរ ព្រោះចន្ទគតិមានទំនាក់ទំនងនឹងពុទ្ធប្បញ្ញត្តិច្រើន។ ចំណែកឯថ្ងៃចូលឆ្នាំតាមចន្ទគតិមិនបានទៀងទាត់ជាថ្ងៃណាមួយទេ ជួនកាលចូលឆ្នាំក្នុងវេលាខ្នើតជួនកាលក្នុងវេលារនោចទៅវិញ។ ប៉ុន្តែនៅក្នុងរវាងមួយខែ គឺមិនមុនថ្ងៃ៤កើត ខែចែត្រ និងមិនហួសថ្ងៃ៤កើត ខែពិសាខទេ ដូចនេះ សង្ក្រាន្តខ្លះធ្លាក់ទៅក្នុងខែពិសាខក៏មាន។

ចំពោះពិធីផ្សេងៗខ្មែរយើងមានរៀបចំតាមប្រពៃណីដូចតទៅនៅពេលមុនចូលឆ្នាំ គេនាំគ្នាប្រុងប្រៀបរកស្បៀងអាហារ សម្អាតផ្ទះសំបែង រែកទឹកដាក់ពាង រកអុសទុកកាត់សម្លៀកបំពាក់ថ្មីៗជាដើម។ ថ្ងៃចូលឆ្នាំមកដល់គេរៀបគ្រឿងសក្ការបូជាសម្រាប់ទទួលទេវតាឆ្នាំថ្មី មានបាយសីមួយគូ ស្លាធម៌១គូ ធូប៥ ទៀន៥ ទឹកអប់១គូ ផ្កាភ្ញី លាជ ទឹក១ផ្តិល និងភេសជ្ជៈ នំនែក ផ្លែឈើគ្រប់មុខ។ ចំណែកផ្ទះសំបែងគេតុបតែងរំលេចដោយអំពូលអគ្គិសនីខ្សែតូចៗចម្រុះពណ៌ ឬចង្កៀងគោមគ្រប់ពណ៌សម្រាប់ទទួលទេវតាឆ្នាំថ្មី។

លុះដល់វេលាកំណត់ទេវតាថ្មី ចុះមកហើយ គេនាំកូនចៅអង្គុយជុំគ្នានៅជិតកន្លែងរៀបគ្រឿងសក្ការៈនោះ ហើយអុជទៀនធូប បាញ់ទឹកអប់បន់ស្រន់សុំសេចក្តីសុខចម្រើនគ្រប់ប្រការពីទេវតាថ្មី។ ចំពោះគ្រឿងសក្ការៈ និងក្រយាស្ងោយដាក់ថ្វាយទេវតានោះ គេនិយមតម្រូវតាមចិត្តទេវតាដែលនឹងត្រូវចុះក្នុងឆ្នាំនីមួយៗ។

**ឧទាហរណ៍:** បើទេវតាដែលត្រូវចុះមកនោះ សោយល្ង សណ្តែក គេដាក់សណ្តែក ល្ងថ្វាយឯពិធី៣ថ្ងៃនៃថ្ងៃចូលឆ្នាំនោះ

* **ថ្ងៃទី១:** គេយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត។ ពេលល្ងាចគេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយនៅជុំវិញព្រះវិហារ ឬនៅជុំវិញដើមពោធិ៍ណាមួយនៅក្នុងវត្តនោះ។ នៅពេលព្រលប់គេប្រគេនភេសជ្ជៈដល់ព្រះសង្ឃនិមន្តលោកចម្រើនព្រះបរិត្ត និងសម្តែងធម្មទេសនា។

* **ថ្ងៃទី២:** កូនចៅជូនសម្លៀកបំពាក់នំចំណីលុយកាក់ដល់អ្នកមានគុណមានឪពុកម្តាយ ជីដូនជីតាជាដើម។ ជួនកាលគេធ្វើទានដល់មនុស្សបម្រើ ឬអ្នកក្រីក្រទៀតផង។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចចូឡាមណីចេតិយ ហើយនិមន្តព្រះសង្ឃបង្សុកូលចេតិយបញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានស្លាប់ទៅ។

* **ថ្ងៃទី៣:** ពេលព្រឹកនិមន្តព្រះសង្ឃឆ្លងភ្នំខ្សាច់ពេលល្ងាចនិមន្តព្រះសង្ឃស្រង់ទឹក និងស្រង់ព្រះពុទ្ធរូប (តាមការនិយមនៃស្រុកខ្លះ) នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គេនាំគ្នាលេងល្បែងប្រជាប្រិយកម្សាន្តសប្បាយជាច្រើន ដូចជាលេងបោះអង្គុញ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែងចាប់កូនខ្លែងជាដើម និងមានរបាំត្រុដិ (ច្រើនមាននៅខេត្តបាត់ដំបង សៀមរាប) ជាពិសេសទៀតគឺរាំវង់តែអាស្រ័យទៅតាមការនិយមចូលចិត្តរបស់មនុស្សតាមតំបន់ ខ្លះនិយមនាំគ្នាដើរកម្សាន្តបន្ត ខ្លះនិយមធ្វើបុណ្យទានតាមវត្តអារាម៕

# ចំណាយ១៣ដុល្លារ ជាវកែវរចនាដោយយុវតីខ្មែរតាម Online ដើម្បីជួយដល់គ្រួសារខ្វះខាតទឹកស្អាតក្នុងប្រទេសកម្ពុជា

**ដោយ សុខាវ័ត្ត កួយ**

នៅតាមបណ្តាញអនឡាញជាពិសេស គឺ AMAZON មានការដាក់លក់កែវដែលមានយីហោ STELLA ARTOIS ដែលបានរចនាឡើយ ដោយក្រុមវិចិត្រករល្បីៗជាច្រើនប្រទេស ក្នុងនោះក៏មានកម្ពុជាផងដែរ ក្នុងតំលៃ១៣ ដុល្លារ សម្រាប់កែវមួយដែលការចំណាយទិញកែវមួយវាស្មើរនឹងការជួយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារ១សម្រាប់រយៈពេល៥ឆ្នាំ ក្នុងប្រទេសកំពុងអភិវឌ្ឍន៏។

កាលពីពេលថ្មីៗនេះមានសកម្មភាពនៃការដាក់លក់កែវ គឺផ្តើមចេញពីកិច្ចសហការគ្នារវាងក្រុមហ៊ុន Stella Artoist ដែលជាក្រុមហ៊ុនស្រាបៀរដ៏ល្បីក្នុងពិភលោកដែលមានប្រវត្តិជិត៦00 ឆ្នាំ និងអង្គការ Water.org ដែលបង្កើតឡើងដោយលោក Gary White និង Matt Damon ដែលជាតារាសម្តែងហូលីវូតាមរយៈយុទ្ធនាការមួយដែលមានឈ្មោះថា "Buy A Lady A Drink"។ យុទ្ធនាការនេះ មានគោលបំណងធំពីរ គឺដើម្បីបង្កើតឱ្យមានការយល់ដឹងទូទាំងពិភពលោកអំពីបញ្ហាទឹកដែលវាកំពុងប៉ះពាល់ប្រទេសកំពុងអភិវឌ្ឍន៏ភាគច្រើនបំផុត ដូចជាតំបន់អាស៊ីអាគ្នេយ៏, អាស៊ីខាងត្បូង, អាមេរិកខាងត្បូង និងផ្នែកជាច្រើននៃអាហ្វ្រិច ជាពិសេសស្ត្រី និងក្រុមគ្រួសារ ដែលរងផលប៉ះពាល់ខ្លាំងជាងគេបំផុត ដោយសារតែស្ត្រីមានតួនាទីក្នុងការថែរក្សាកូនផង និងជាអ្នកដែលធ្វើដំណើរដ៏ឆ្ងាយទៅយកទឹកសម្រាប់គ្រួសារ និង





ដើម្បីប្រមូលថវិការជួយដល់ប្រជាពលរដ្ឋដែលខ្វះខាត់ទឹកស្អាត់ប្រើប្រាស់ទូទាំងពិភពលោក។

ក្នុងយុទ្ធនាការឆ្នាំនេះ វិចិត្រករចំនួន៣ ប្រទេសមានដូចជាកម្ពុជា, ប្រេស៊ុល, និងយូក្រានដា ត្រូវបានជ្រើសរើសដើម្បីធ្វើការរចនាគំនួរលើកែវតំណាងឱ្យប្រទេសរៀង១ខ្លួន។ សម្រាប់កម្ពុជាវិចិត្រការិនី ម៉ម លីសា ត្រូវបានក្លាយជាអ្នកតំណាងកម្ពុជាក្នុងការរចនាគំនួរសម្រាប់គម្រោងមួយនេះ។ ថ្លែងតាមសារអេឡិចត្រនិចកញ្ញា ម៉ម លីសា ថា ខ្ញុំពិតជាមានកត្តិយសណាស់ដែលត្រូវបានជ្រើសរើសជាតំណាងកម្ពុជា និងក៏ជាវិចិត្រករដើម្បីធ្វើការរចនាគំនួរលើកែវសម្រាប់តំណាងកម្ពុជា..។ កញ្ញា លីសា បានបន្តថា សម្រាប់រូបគំនូរដែលបង្កើតឡើងនេះគឺជាការរចនា និងការយល់ឃើញរបស់កញ្ញាផ្ទាល់ដោយមានការរចនាតាមបែបខ្មែរទំនើបតែមានទំនោរជាការរចនាតុបតែងតាមបែបប្រពៃណីបុរាណខ្មែររបស់យើង ហើយមានលក្ខណៈសាមញ្ញដោយរូបនេះ គឺមានន័យថាទឹកផ្តល់នូវជីវិត។ ផ្នែកដែលសំខាន់បំផុតគឺរូបគំនូរទាំងអស់មានទំនាក់ទំនងគ្នាដោយមាន









រូបស្ត្រីយកដៃទ្រដំណកទឹក និងផ្តល់ជីវិតដល់បរិដ្ឋានទាំងអស់ដែលកំពុងរីកលូតលាស់នៅជុំវិញដែលជាធាតុផ្សំនៃធម្មជាតិ ។

លីសា ក៏បានបន្តទៀតថា កែវនេះត្រូវបានដាក់លក់នៅ Amazon.com ក្នុងតម្លៃ១៣ ដុល្លារអាមេរិកសម្រាប់កែវមួយហើយប្រាក់ដែលបានមកពីការលក់នេះនឹងត្រូវប្រើប្រាស់ ដើម្បីជួយដំឡើងទឹកស្អាតដល់គ្រួសារដែលទទួលរងបញ្ហាផ្នែកសុខភាពដោយសារបញ្ហាកង្វះទឹក។ កញ្ញាក៏បានលើកឡើងថា រាល់ការចំណាយថវិការក្នុងការទិញកែវមួយ គឺវាស្មើនឹងការជួយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារ១សម្រាប់រយៈពេល៥ឆ្នាំ។ រហូតមកដល់ពេលនេះ កែវចំនួនច្រើនជាង៣00,000 ហើយត្រូវបានលក់ ដូច្នេះមានន័យថា គ្រួសារចំនួនច្រើនជាង៣00,000 ហើយ ដែលត្រូវបានជួយឱ្យមានទឹកស្អាត់ប្រើប្រាស់ដល់លំនៅដ្ឋានរបស់ពួកគេ។

សូមបញ្ជាក់ថា ម៉ម លីសា បានបញ្ចប់ការសិក្សាថ្នាក់ទន្តសាស្ត្រនៅសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលកាលពី ២ ឆ្នាំមុន ហើយបច្ចុប្បន្ននេះ លីសាជាទន្តបណ្ឌិត។ កញ្ញាពុំបានចូលរៀនគូគំនួរនៅសាលារៀននោះទេ តែដោយសារតែទេពកោសលើពីធម្មជាតិ, ការស្រលាញ់សេរីភាព និងចំណងចំណូលចិត្តក្នុងការគូរតាំងពីក្មេងដែលកើតចេញពីការឃើញរូបគំនូរតាមទីសាធារណៈនៅពេលរធ្វើដំណើរទៅប្រទេសបារាំងជាច្រើនដងជាមួយគ្រួសារទាំងនេះគឺជាធាតុផ្សំចំបងបំផុតដែលធ្វើឱ្យ លីសា អាចបញ្ចេញទេបកោសលនៃការគូគំនូរដោយមានសេរីភាព និងការច្នៃប្រឌិតដោយខ្លួនឯង ហើយធ្វើឱ្យយុវតីមួយរូបនេះហាក់ទទួលបានជោគជ័យក្នុងអាជីបសិល្បៈរហូតដល់បច្ចុប្បន្ននេះ។ លីសា ថា ការគូរគំនូរ គឺជាអ្វីដែលនាងចូលចិត្តធ្វើពីមុនការគូរគឺអ្វីដែលកញ្ញាចូលចិត្តនៅពេលមានមានទំនេរប៉ុណ្ណោះ តែឥឡូវនេះការគូរវាគឺជាអ្វីដែលកញ្ញាចំណាយពេលធ្វើភាគច្រើនបំផុត។

ស្នាដៃរបស់ លីសា ដែលត្រូវបានចាប់ផ្តើមទទួលស្គាល់ និងមានការចាប់អារម្មណ៏យ៉ាងខ្លាំងពីសំណាក់ប្រជាជនក្នុងស្រុកគឺរូបគំនូរលើជញ្ជាំងនៅជុំវិញក្រុងភ្នំពេញ ហើយឯសម្រាប់បរទេសវិញ គឺចាប់តាំងពីកញ្ញាបានរចនាម៉ូតស្បែកជើងឱ្យក្រុមហ៊ុន Bucketfeet ដែលមានទីតាំងនៅ Chicago សហរដ្ឋអាមេរិក។ ជាចុងក្រោយ លីសា ថា ខ្ញុំសូមអរគុណចំពោះការគាំទ្រនូវការងារសិល្បៈរបស់នាង ហើយខ្ញុំក៏ចងប្រាប់ថា អ្វីក៏ដោយឱ្យតែអ្នកមានចំណង់ចំណូលចិត្ត និងក្តីស្រមៃអ្នកគួរតែធ្វើទៅតាមអ្វីដែលអ្នកជឿជាក់ការប្រគួតប្រជែងតែមួយគត់របស់អ្នក គឺខ្លួនអ្នកផ្ទាល់គ្មាននរណាផ្សេងនោះទេ គិតអ្វីដែលល្អ និងមានការយល់ឃើញវិជ្ជមានទៅលើអ្វីៗដែលអ្នកធ្វើ និងអ្វីៗដែលនៅជុំវិញអ្នក ..៕









# NOTICE OF PUBLIC MEETING

# សេចក្តីជូនដំណឹង ការរៀបចំកិច្ច ប្រជុំជាសាធារណៈ

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet at 2:30 P.M.on April 26, 2017 at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, Lowell, MA. The NMMPO will vote to release the draftFFY 2018-2022 Transportation Improvement Program (TIP) and the draft FFY 2018 Unified Planning Work Program (UPWP).The full agenda can be found at www.nmcog.org. Please note that the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The MPO's public participation process satisfies the LRTA's public participation requirements for the program of projects.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance, free of charge, upon request (including, but not limited to, interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

អង្គភាពរៀបចំក្រុង ន័សធន មុីដូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO នឹងរៀបចំកិច្ចប្រជុំជាសាធារណៈមួយនៅម៉ោង២:៣០នាទីរសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ នៅការិយាល័យក្រុមប្រឹក្សាភិបាលន័សធនមុីដូលសិច( Northern Middlesex Council of Governments) ដែលមានទីតាំងស្ថិតនៅផ្លូវ 40Church Street, Suite 200, Lowell, MA ។ ក្នុងជុំនួបនេះអង្គភាព NMMPO នឹងធ្វើការបោះឆ្នោត ដើម្បីធ្វើការផ្សព្វផ្សាយពង្រៀងគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន(TIP) FFY ឆ្នាំ ២០១៨-២០២២ និងពង្រៀងកម្មវិធីផែនការសកម្មភាពនៃការបង្រួមបញ្ចូលគ្នាគម្រោង FFY ២០១៨។

លោកអ្នកអាចទទួលបានព័ត៌មានពីរបៀបវិរៈនៃកិច្ចប្រជុំនេះទាំងស្រុងដោយគ្រាន់តែចូលទៅកាន់វេបសាយ www.nmcog.org នេះ។ សូមបញ្ជាក់ថា ក្នុងគម្រោង TIP នេះក៏មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើនសម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA)ផងដែរ។ ដំណើរការចូលរួមជាសាធាណៈរបស់អង្គភាពរៀបចំក្រុងនេះ គឺវាស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន។

**កំណត់ចំណាំ:**

ទីតាំងនៃការរៀបចំកិច្ចប្រជុំនេះ ងាយស្រួលសម្រាប់ឱ្យជនពិការចេញចូល និងនៅជិតនិងចំណតឡានក្រុង។ អង្គភាព NMMPO មានទីតាំងសុវត្ថិភាពសម្រាប់ចំណតកង់ដែលស្ថិតនៅជាន់ទី២។ សម្រាប់ជុំនួបនេះ NMMPO ក៏ផ្តល់ផងដែរនូវការស្នាក់នៅដ៏សមរម្យ និង,រឺជំនួយផ្នែកភាសាដោយមិនគិតថ្លៃ ប្រសិនបើមានការស្នើរសុំ( មានដូចជាអ្នកបកប្រែជាភាសាអងគ្លេស និងភាសាផ្សេងទៀត, បកប្រែភាសាដោយមើល រឺស្តាប់តាមរយៈវីដេអូសម្រាប់អ្នកពិការភ្នែក និងថ្លង់, ឧបករណ៍បកប្រែជាសម្លេងសម្រាប់អ្នកគរ ថ្លង់ និងជនពិការភ្នែក ព្រមទាំងការចែកជូនឯកសារផ្សេងទៀតបុតាមដែលមាន ។

សម្រាប់ការចូលរួមរបស់លោកអ្នក និងជំនួយបន្ថែម សូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរស័ព្ទ (978) 454-8021, ខេត ១២១ រឺអ៊ីមែលទៅកាន់ jhoward @nmcog.org ។ រាល់ការស្នើរសុំជំនួយនានាដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីងាយស្រួលក្នុងការរៀបចំ ៕

# ចម្លាក់អប្សរាតំណាងឱ្យប្រទេសកម្ពុជា មានវត្តមាននៅអាមេរិក

**ដោយ សុខាវ័ត្ត កួយ**

ឡុងប៊ិច- ដើម្បីបង្កើនការយល់ដឹងជាសាធារណៈពីអត្ថប្រយោជន៍នៃឈើ និងតើឈើមានតួនាទីសំខាន់បែបណាសម្រាប់អនាគតប្រកបដោយនិរន្តរភាពនោះ កម្មវិធី World Wood Day (WWD) ត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំនៅថ្ងៃទី ២១ ខែមិនា ដោយមានការសហការគ្នារវាងមូលនិធិ World Wood Day Foundation និងអង្គការ International Wood Culture Society ។



សម្រាប់ឆ្នាំ២០១៧កម្មវិធី WWD នេះ បានរៀបចំឡើងដោយមានរយៈពេលពេញមួយសប្តាហ៍ ចាប់ពីថ្ងៃទី២១ ដល់២៦ ខែមិនា ឆ្នាំ២០១៧ ដែលប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលកម្សាន និងសន្និបាទឡុងប៊ិចនៅក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាមេរិកដោយមានកម្មវិធីសំខាន់ៗដូចជាកម្មវិធីធ្វើរបស់ពីឈើ (មានការចម្លាក់, ការខៃ, និងការធ្វើគ្រឿងសង្ហារឹមដោយយុវជន), រោងជាងចំលាក់រូបសិល្បៈ, ការដាំដើមឈើ និងការតាំងពិពណ៌ជាដើម ។

កម្មវិធី ២០១៧ World Wood Day នៅក្រុងឡុងប៊ិចនេះមានអ្នកចូលរួមប្រមាណជាង២០០នាក់មកពីប្រទេសចំនួន១៦០ទូទាំងពិភពលោក។ អ្វីដែលគួរឱ្យកត់សម្គាល់ប្រទេសកម្ពុជា ក៏មានតំណាងចំនួនពីររូបត្រូវបានអញ្ជើញមកចូលរួមក្នុងព្រឹត្តការណ៍នេះផងដែរ គឺលោក ហៃ សុកលីម អនុប្រធានការិយាល័យសូនរូប និងសិប្បកម្មនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងលោក រីម រឿន តំណាងឱ្យជាងចម្លាក់កម្ពុជា ។




លោក រីម រឿន (ឆ្វេង) និងលោក ហៃ សុកលីម(ស្តាំ) កំពុងឆ្លាក់រូបអប្សរាក្នុងកំឡុងពេលកម្មវិធី

លោក ហៃ សុកលីម បានប្រាប់ Khmerpost តាមទូរស័ព្ទឱ្យដឹងថានេះ គឺជាលើកទីពីរហើយសម្រាប់រូបលោកដែលបានចូលរួមកម្មវិធី WWD នេះ ដោយលើកទីដំបូងនៅឆ្នាំ២០១៦ លោកបានចូលរួមកម្មវិធីនេះនៅប្រទេសណេប៉ាល់ និងលើកទី២នេះ គឺនៅសហរដ្ឋអាមេរិក”។ លោកបានបន្តថា “ការចូលរួមលើកនេះ ដោយសារតែវេលាមានកំណត់យើងបានជ្រើសរើសយករូប “អប្សរា” មកធ្វើការឆ្លាក់លើឈើដែលមានទំហំកម្ពស់ប្រហែល១ម៉ែត្រ និងទទឹង០.៥ម៉ែត្រជាតំណាងប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងកម្មវិធីនេះ”។

សម្រាប់រូបអប្សរានេះ ត្រូវចំណាយពេល៥ថ្ងៃក្នុងកំឡុងពេលចូលរួមកម្មវិធីដើម្បីធ្វើឱ្យរួចរាល់ និងយកទៅដាក់តាំងបង្ហាញនៅថ្ងៃបញ្ចប់ ហើយបន្ទាប់ពីបញ្ចប់កម្មវិធីរូបចម្លាក់តំណាងប្រទេសនិមួយៗទាំអស់នឹងត្រូវរក្សាទុកនៅសារមន្ទីក្រុងឡុងប៊ិច នេះបើតាមការលើកឡើងរបស់លោកសុកលីម ។ ដោយឡែកលោក រីម រឿន វិញនិយាយថា លោកមោទនភាពដែលត្រូវបានអញ្ជើញមកចូលរួមកម្មវិធីនៅសហរដ្ឋអាមេរិកនេះ និងបានផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹងទៅវិញទៅមកជាមួយបណ្តាប្រទេសផ្សេងទៀតផងដែរ ៕




# តម្រឹមធ្មេញដោយមិនយកថ្លៃ

ប្រសិនបើលោកអ្នកឬគ្រួសារ មានអាយុ២១ឆ្នាំ ឬក្មេងជាង សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ
ដើម្បីរកមើលថាតើលោកអ្នកមានសិទ្ធនឹងទទួលបាននូវ “ប្រដាប់តម្រឹមធ្មេញ”ដោយ មិនចំណាយប្រាក់
ឬទេនៅពេលលោកអ្នកមាន“ម៉ាសហ៊ែល”? លោកអ្នកអាចនឹងទទួលសំណងរហូតដល់៤,៣០០ដុល្លា
សម្រាប់ដាក់“ប្រដាប់តម្រឹមធ្មេញ”ទៅតាមសេចក្តីត្រូវការរបស់អ្នក។

The BRACES PLACE

វេជ្ជបណ្ឌិត មូហាប់ រីសកាឡា DDS MSD

## តើយើងធ្វើអ្វីខ្លះ?

ដាក់ធ្មេញដោយដែក * ដោយមាស * ដោយ“អិនវីសាឡាញ” * ដោយចាន

## អ្វីដែលធ្វើឱ្យយើងប្រសើរជាងនោះ?

- ឆ្លុះមើលបន្ថែម នឹង ជួបគ្រូពេទ្យ
- យើងទទួលយក“ម៉ាសហ៊ែល” នឹង “អិនស៊ូរិន”ផ្សេងៗទៀត
- បង់ប្រាក់កក់មុនតិចបំផុត នឹងមានវិធីបង់ប្រាក់រំលោះប្រចាំខែសម្រាប់អ្នកដែលគ្មាន“អិនស៊ូរិន” សូមទូរស័ព្ទ ឬក៏មកកន្លែងដែលស្រួលរករបស់យើង

710 Chelmsford St. Lowell, MA 01851
**(978)- 454 - 0774** (មានអ្នកនិយាយភាសាខ្មែរ)
ដើម្បីបានព័ត៌មានបន្ថែម, សូមចូលទៅ“វេបសាយ”យើង: www.bracesplaces.com

PLEASE JOIN US FOR THE EVENT

WOMEN IN THE TRADES



COME AND LEARN HOW YOU CAN HAVE A SUCCESSFUL & REWARDING CAREER IN THE TRADES




WHEN
SATURDAY
APRIL 29
10:00AM - 1:00PM

WHERE
PCTA
PROVIDENCE
CAREER AND TECHNICAL ACADEMY
41 FRICKER STREET
PROVIDENCE, RI 02903

SPONSORS

- Rhode Island Building and Construction Trades Council
- RIDOA - Office of Diversity Equity & Opportunity (ODEO)
- Providence Public Schools
- RIDOT
- RI Commission on Women and Girls
- YWCA Rhode Island
- Building Futures
- Women's Fund of RI
- The Center for Women & Enterprise (CWE)
- Opportunities Industrialization Center - (OIC)
- NAWIC RI
- Rhode Island Indian Council

FOR MORE INFORMATION CALL VICTOR MENDOZA
401-222-3900 OR VISIT WWW.ODEO.RI.GOV
TO REGISTER, GO TO: HTTPS://WWW.EVENTBRITE.COM/E/WOMEN-IN-THE-TRADES-TICKETS-33588442937

PICTURES SOURCE: OREGON TRADESWOMEN, INC./DAWN JONES REDSTONE

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៍ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័ត៌មានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial
45, Merrimack Street, #218A
Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

យើងជឿជាក់ថា គំនិត យោបល់ នឹងព័ត៌មានពីលោកអ្នកនឹងជួយជាប្រយោជន៍ដល់សហគមន៏ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**

**កាសែតដែលបំរើសហគមន៍ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់ នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ**

KhmerPost USA, LLC

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Richard Howe Jr,
**ច្នៃសោភ័ណភាពកាសែត Design Artist**
Heng Chhunleng
**ជំនួយការរដ្ឋបាល** Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

**តមកពីទំព័រទី ០៩** មហាសង្ក្រាន្តឆ្នាំថ្មី ឆ្នាំរកា...




បីថ្ងៃសេច្រចបរិបូណ៌ចូលជាសកល ឆ្នាំរកាន ព្វស័ក និង ម.ស.១៩៣៩ ចុ.ស.១៣៧៩ តទៅ។

**វណ្ណាប់ទទួលទេវតា**

វណ្ណាប់ទទួលទេវាតា តាមទំនៀមបុរាណរៀងរហូតមក ត្រូវរៀបរានទទួលទេវតានៅខាង មុខផ្ទះមួយសម្រាប់តាំងគ្រឿងពលីការផ្សេងៗ។ ត្រូវរៀបក្រាលសំពត់ពណិស ហើយរៀបចំនូវគ្រឿងសក្ការបូជាទេវាតាមានជាអាទិ៍បាយសី៩ថ្នាក់ មួយគូ បាយសី៧ថ្នាក់មួយគូ បាយសី៥ថ្នាក់ មួយគូ បាយសី៣ថ្នាក់មួយគូ បាយសីប៉ាឆាម មួយគូ ស្លាធមិមួយគូ ទឹកអប់មួយគូ ទៀន៥ធូក ៥ លាច៥ផ្កា៥ ដាក់លើជើងពាន ១គូ ចេកនួន ចេកណាំវ៉ា ដាក់លើជើងពានមួយគូ ផ្លែឈើ១១មុខ រៀបដាក់ជើងពាន១១គូ ដូងឡៅមួយគូ ទឹកស្អាត២កែវ។ ស្រេចហើយនៅវេលាម៉ោងដែលទេវតាចុះមកត្រូវជួបប្រជុំក្រុមគ្រួសារ ដើម្បីថ្វាយបង្គំព្រះនមស្សការព្រះរតនៈត្រ័យសមាទានសីលហើយតាំងចិត្តឱ្យបានបរិសុទ្ធជ្រះស្រឡះនូវមន្ទិលទាំងពួងតម្កល់ចិត្តរំពឹង គិតទៅលើ ព្រះពុទ្ធ ព្រះធមិ ព្រះសង្ឃជាទីពឹងទីរឭក លុះចប់ពិធីទទួលទេវតា។

ចំពោះបាយសី៩ថ្នាក់ ៧ថ្នាក់ ជាទំនៀមមានចែងក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាស និងមានអនុវត្តនៅព្រះបរមរាជវាំង តែចំពោះប្រជារាស្រ្តគួរធ្វើត្រឹម៥ថ្នាក់ ចុះមក ឬរៀបត្រឹមគ្រឿងសក្ការបូជា ដែលមានទៀនប្រាំ ធូបប្រាំ ស្លាធមិកូនចេកមួយគូ ក៏ល្មមសមគួរដែរ។ ចំពោះផ្លែឈើសម្រាប់ប្រជារាស្រ្ត គួររៀបឱ្យបានត្រឹម៣ឬ៥មុខក៏ជាការប្រសើរ គឺរៀបទៅតាមធនធានរបស់ខ្លួន។ នៅគ្រប់ដង្វាយទាំងអស់ត្រូវដាក់ផ្កាម្លិះភ្ញួងពីលើគ្រប់ដង្វាយនៅលើជើងពាន និងលើបាយសីត្រូវដោតទៀនដុតបំភ្លឺ៕

( អស័យដ្ឋានអ្នកផ្ញើរ )

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២.......................................................................................................

**អត្ថបទក្នុងសំបុត្រនេះ**
**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ


MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com



Element Care
ខ្ញុំគ្មានការព្រួយបារម្ភទៀតទេ។



- ការផ្តល់សេវាធ្មេញដោយឥតគិតថ្លៃ
- ការផ្តល់ជូននូវយានជំនិះដោយឥតគិតថ្លៃ
- ផ្តល់ជូនវ៉ែនតានិងឧបករណ៍ជំនួយការស្តាប់ដោយឥតគិតថ្លៃ
- ការថែទាំតាមផ្ទះនិងផ្តល់ជូននូវអាហារដោយឥតគិតថ្លៃ
- ផ្តល់ជូននូវថ្នាំតាមវេជ្ជបញ្ជាដោយឥតគិតថ្លៃ

នៅជាមួយនឹងកម្មវិធី PACE នៃអង្គការ Element Care, ការថែរក្សានឹងការចំណាយរបស់ខ្ញុំគឺត្រូវបានទទួលខុសត្រូវទាំងស្រុងជំនួសខ្ញុំ។

អ្នកដែលមានសិទ្ធិមាន MassHealth នឹង Medicare គឺមិនត្រូវបង់ថ្លៃទេ។ សូមទាក់ទងមកយើងខ្ញុំបើអ្នកមានតែ Medicare ហើយនឹងការបង់ថ្លៃដោយឯកជន។ គ្រប់សមាជិកទទួលបាននូវការថែទាំសុខភាព, សេវាកម្មពេទ្យឯកទេស-លើកលែងតែសេវាកម្មសង្គ្រោះបន្ទាន់-ដូចជាបានអនុញ្ញាតពីកម្មវិធី PACE, ពុំនោះទេនឹងទទួលខុសត្រូវដោយខ្លួនឯងចំពោះថ្លៃសេវាកម្មមិនបានអនុញ្ញាតជាមុន។
H2222_2016_3K

សូមអញ្ជើញទាក់ទងមកកាន់ទូរសព្ទលេខខាងក្រោមនេះ
1-877-803-5564
(TTY 711)
ឬក៏តាមរយៈ:
elementcare.org

សារព័ត៌មាន ខ្មែរផុស ស.រ.អា

# KhmerPost USA

*Cambodian American Biweekly Newspaper*

## ផ្សព្វផ្សាយទៅដល់អ្នកអានក្នុងសហគមន៍ខ្មែរច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិក

កាសែតខ្មែរផុស ស.រ.អា គឺជាកាសែតភាសារខ្មែរ- អង់គ្លេសពណ៌ធម្មជាតិ មានចំនួន៣២ទំព័រដែលបោះពុម្ពផ្សាយជារៀងរាល់ពីរសប្តាហ៍ម្តងចំនួន៥,០០០ច្បាប់ និងធ្វើការបែងចែកដោយមិនគិតថ្លៃទៅកាន់៦០កន្លែងក្នុងតំបន់ឡូវែល។ រៀបចំពេលវេលាផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៧ របស់លោកអ្នកជាមួយយើងខ្ញុំថ្ងៃនេះ!

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

| <u>កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ :</u> | <u>**2017 Print Dates**</u> |
|---|---|
| ថ្ងៃទី ៧ និង ២១ ខែមេសា | April 7, 21 |
| ថ្ងៃទី ៥ និង ១៩ ខែឧសភា | May 5, 19 |
| ថ្ងៃទី ៩ និង ២៣ ខែមិថុនា | June 9, 23 |
| ថ្ងៃទី ៧ និង ២១ ខែកក្កដា | July 7, 21 |
| ថ្ងៃទី ៤ និង ១៨ ខែសីហា | August 4, 18 |
| ថ្ងៃទី ៨ និង ២២ ខែតុលា | September 8, 22 |
| ថ្ងៃទី ៦ និង ២០ ខែកញ្ញា | October 6, 20 |
| ថ្ងៃទី ៣ និង ១៧ ខែវិច្ឆិការ | November 3, 17 |
| ថ្ងៃទី ៨ និង ២២ ខែធ្នូ | December 8, 22 |




* រាល់ព័ត៌មាននៃការផ្សព្វផ្សាយទាំងអស់ ត្រូវផ្ញើមកកាន់យើងខ្ញុំឲ្យបាន ៣ ថ្ងៃមុនការបោះផ្សាយ។

**ទំនាក់ទំនងមក ពិន សុបិន សម្រាប់ឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរបស់លោកអ្នក**

**Contact Soben Pin For Advertising Opportunities**
**Email: sobenpin@khmerpost.us**
**978-677-7163**

ម៉ោងបំរើការងារ: ថ្ងៃច័ន្ទ - សុក្រ ចាប់ពី 9:00 ព្រឹក ដល់ម៉ោង ៤:00 ល្ងាច
អសយដ្ឋានការិយាល័យ**កាសែតខ្មែរផុសស.រ.អា**

Office: KhmerPost USA, LLC. 45 Merrimack St. Suite 218A. Lowell, MA 01852
Hours: Monday – Friday. 9AM – 4PM
**VISIT KHMERPOST.US**

KhmerPost USA

សូមគោរពអញ្ជើញ លោក លោកស្រី ចូលរួមរាត្រីស្រមោលស

## ខួបទី១០ឆ្នាំ នៃការបង្កើត សារព័ត៌មានខ្មែរផុស ស.រ.អា

ថ្ងៃសុក្រ ទី19 ខែឧសភា ឆ្នាំ 2017

6:00 -12:00 ល្ងាច

**នៅសណ្ឋាគារ យូម៉ាស ឡូវែល**

50 Warren Street
Lowell, Massachusetts

**5:30** ពិសារ( ខុកថែល ) - ជាមួយអាហារសំរន់

**6:30** ការសម្តែងរបាំប្រពៃណី
អាហារពេលល្ងាច
ការរាំកំសាន្តជាមួយក្រុមភ្លេងតន្ត្រីខ្មែរ
អាចទិញភេសជ្ជៈជូនពិសារបាន

ស្លៀកពាក់ របៀបប្រពៃណីខ្មែរ ឬរបៀប( បូលហេម )
តម្លៃសំបុត្រ $75 ក្នុងមួយនាក់ $700 សម្រាប់ 10 នាក់
មិនមានការលក់សំបុត្រនៅថ្ងៃកម្មវិធីនោះទេ

សូមទាក់ទងដើម្បីជាវសំបុត្រឲ្យបានមុនថ្ងៃពុធ ទី10 ខែឧសភា
សំខុន ពិន: **978-942-1641** | សូបិន ពិន: **978-677-7163**
សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅគេហទំព័រ khmerpost.us




Cordially invites you to our

# 10th Year Anniversary Gala

**Friday, May 19, 2017**

**6:00PM – 10:30PM**

**UMASS Lowell Inn & Conference Center**

50 Warren Street, Lowell, Massachusetts

**COCKTAIL HOUR 5:30-6:30 SERVING HORS D'OEUVRES**
**CULTURAL PERFORMANCES |DINNER**
**LIVE BAND & DANCING | CASH BAR| SILENT AUCTIONS**

BLACK TIE OPTIONAL
$75 per ticket | $700 per table of 10
No Tickets Sold at the Door

**Please RSVP by Friday May 10th**

**Contact: 978-677-7163 or sobenpin@khmerpost.us**